


# តើធ្វើយ៉ាងណាឱ្យវារីអគ្គិសនីកាន់តែមាន និរន្តរភាពថែមទៀត?

## វិធានមួយសំរាប់ការវាស់កម្រិតនិរន្តរភាព ដែលនាំមុខដោយវេទិកាវិភាគវាយតំលៃ អំពីនិរន្តរភាពនៃវារីអគ្គិសនី

**Tira Foran**

M-POWER
Mekong Program on Water Environment and Resilience

# តើធ្វើយ៉ាងណាឱ្យវារីអគ្គិសនីកាន់តែមាននិរន្តរភាពថែមទៀត?

## វិធានមួយសំរាប់ការវាស់កម្រិតនិរន្តរភាព ដែលនាំមុខដោយវេទិកាវិភាគវាយតំលៃអំពីនិរន្តរភាពនៃវារីអគ្គិសនី


រៀបរៀងដោយ

**Tira Foran**

ផ្នែកស្រាវជ្រាវសង្គមនិងបរិស្ថាន មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម សកលវិទ្យាល័យឈៀងម៉ៃ tiraforan@gmail.com

## ACKNOWLEDGMENTS

The author would like to thank Helen Locher, John Dore, Louis Lebel, and Kate Lazarus for numerous helpful comments received. We would like to thank the Blue Moon Fund for their financial support. The cover photo is courtesy of International Rivers.

**តើធ្វើយ៉ាងណាឱ្យវារីអគ្គិសនីកាន់តែមាននិរន្តរភាពថែមទៀត?**

វិធានមួយនៃការវាស់កម្រិតនិរន្តរភាព ដែលនាំមុខដោយវេទិកាវិភាគវាយតំលៃ
អំពីនិរន្តរភាពនៃវារីអគ្គិសនី

By **Tira Foran**

Unit for Social and Environmental Research, Faculty of Social Sciences, Chiang Mai University

© Copyright 2010

All rights reserved. No part of this publication may be reproduced in any form or by any means without written permission from the copyright owner and publisher.

First Published: 2010

Printed in Thailand

# មាតិកា


ប្រវត្តិដើម .......... 2

វិធានឆ្ពោះទៅរកនិរន្តរភាពប្រកាន់យកដោយក្រុមឧស្សាហកម្ម .......... 5

តើចង់ឱ្យពិធីសារនៃការវិភាគវាយតម្លៃអំពីនិរន្តរភាពនៃវារីអគ្គិសនី
មាននាទីបែបណា? .......... 6

កិច្ចការគន្លឹះនានាសម្រាប់តំបន់មេគង្គ .......... 9

ដែនកំណត់ និងសក្តានុពលនៃសេចក្តីព្រាង HSAP .......... 18

សេចក្តីសន្និដ្ឋាន .......... 20

សេចក្តីថ្លែងអំណរគុណ .......... 22

ឯកសារយោង .......... 23



*ឯកសារនេះគឺសម្រាប់បង្កើនការយល់ដឹងអំពីសេចក្តីព្រាងពិធីសារវិភាគវាយតំលៃអំពីនិរន្តរភាពនៃថាមពលវារីអគ្គិសនី(HSAP) ។ សេចក្តីព្រាង HSAP ឆ្នាំ ២០០៩ បានរៀបរៀងឡើងជាឧបករណ៍ សំរាប់វាស់កម្រិតនិរន្តរភាពជាក់ស្តែង ដែលនឹងគាំទ្រ ដោយអ្នកពាក់ព័ន្ធជាច្រើន រួមទាំងសង្គមស៊ីវិលផងដែរ ។*

*ឯកសារនេះ ផ្តល់ការវិភាគដោយឯករាជ្យមួយ ។ យើងប្រៀបធៀបសេចក្តីព្រាង HSAP ជាមួយក្របខ័ណ្ឌនៃការធ្វើសេចក្តីសម្រេចរបស់គណៈកម្មការពិភពលោកស្តីពីទំនប់ WCD ។ យើងសង្កត់ធ្ងន់លើកិច្ចការនានា ដែលគួរតែមានការគិតគូរ និងពិភាក្សាជាបន្ថែម ។ វេទិកាវិភាគវាយតំលៃអំពីនិរន្តរភាពនៃវារីអគ្គិសនីស្វាគមន៍យោបល់ពីសាធារណៈជន លើសេចក្តីព្រាងពិធីសារ HSAP រហូតដល់ខែវិច្ឆិកាឆ្នាំ២០០៩ ។*

ទំនប់វារីអគ្គិសនីខ្នាតធំ ទំនងជាផលិតមិនត្រឹមតែថាមពលអគ្គិសនីប៉ុណ្ណោះទេ ថែមទាំងនាំឱ្យ មានការពិភាក្សា ជជែក វែកញែកជាច្រើនផងដែរ ។ រដ្ឋាភិបាល និងក្រុមហ៊ុនថាមពលនានា មើលឃើញលទ្ធភាពបម្លែងទឹកហូរឱ្យទៅជាថាមពលអគ្គិសនី ជាធនធានសេដ្ឋកិច្ចដ៏មានតម្លៃមួយ ។ អ្នករិះគន់អះអាងថា ទំនប់ខ្នាតធំនៅក្នុងតំបន់មេគង្គ មានការទាក់ទងទៅ នឹងផលប៉ះពាល់ អវិជ្ជមានធ្ងន់ធ្ងរ និង ច្រើនតែមិនអាចដោះស្រាយរួច ទៅលើប្រព័ន្ធអេកូឡូស៊ី និងប្រជាពលរដ្ឋដែលងាយរងគ្រោះ (Molle et al. 2009) ។

នៅក្នុងបរិបទ ដែលច្បាប់ជាតិនៅខ្សោយ ឬការលើកទឹកចិត្តច្បាស់លាស់ខាងសេដ្ឋកិច្ច ដើម្បីកែលម្អស្ថានភាពខាងបរិស្ថាន និងសង្គម កំពុងតែខ្វះខាតនៅឡើយ តើយើង អាចធ្វើអ្វីបានខ្លះ? វិធានមួយ គឺត្រូវចាប់ផ្តើម ដោយស្នើឱ្យ ក្រុមអ្នកអភិវឌ្ឍន៍គម្រោង និងក្រុមផ្សេងទៀតដែលមានចំណាប់អារម្មណ៍ ធ្វើការវិភាគវាយតំលៃដោយគ្មានលំអៀង អំពីនិរន្តរភាពនៃការ អភិវឌ្ឍវារីអគ្គិសនី ។ ឯកសារសង្ខេបនេះ បង្ហាញឱ្យស្គាល់អំពី សេចក្តីព្រាងពិធីសារវិភាគវាយតំលៃអំពីនិរន្តរភាពនៃ ថាមពលវារីអគ្គិសនី ដែលគាំទ្រ ដោយសមាគមវារីអគ្គិសនីអន្តរជាតិ (IHA) ។

នៅឆ្នាំ ២០០៧ ក្រោមកិច្ចសហការជាមួយអង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធនធានសត្វព្រៃ (WWF) និងអង្គការអភិរក្សធម្មជាតិ (TNC) សមាគមវារីអគ្គិសនីអន្តរជាតិ (IHA) បានបង្កើត "វេទិកាវិភាគវាយតំលៃ អំពីនិរន្តរភាពរបស់ វារីអគ្គិសនី"(HSAF) ។ វេទិកានេះផ្តោតលើការពិនិត្យឡើងវិញ និងផ្តល់យោបល់ ដើម្បីកែលម្អពិធីសាររបស់ IHA សម្រាប់វិភាគវាយតំលៃកម្រិតនិរន្តរភាពនៃវារីអគ្គិសនី (IHA 2006) ។ នៅក្នុងវេទិកានេះ មានការចូលរួមរបស់តំណាងមកពី វិស័យឧស្សាហកម្ម រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (NGOs) ចំនួនបួន ។ នៅឆ្នាំ ២០០៨-២០០៩ សមាជិករបស់ HSAF បានធ្វើការជាមួយគ្នា ដើម្បីកែលម្អវិធីសម្រាប់វិភាគវាយតំលៃ ដោយមានគោលដៅបង្កើតឧបករណ៍មួយដែលគ្មានលំអៀង និងដែលមានសារប្រយោជន៍ សម្រាប់ការប្រើប្រាស់ទូលំទូលាយ ។ វេទិកានេះបានចេញផ្សាយ សេចក្តីព្រាងពិធីសារវិភាគវាយតំលៃអំពីនិរន្តរភាព នៃវារីអគ្គិសនី នៅខែសីហា ឆ្នាំ២០០៩ ។

## សេចក្តីព្រាងពិធីសារវិភាគវាយតំលៃអំពីនិរន្តរភាពនៃ វារីអគ្គិសនី (ពង្រាង HSAP)

សេចក្តីព្រាង HSAP គឺជា សមិទ្ធផលមួយនៃការចរចា ដែលផ្អែកលើការយល់ស្របគ្នា រវាងសមាជិក នៃវេទិកានេះ ។ ការងាររបស់វេទិកានេះ បានទាក់ទាញឱ្យមានការគាំទ្រ និងការរិះគន់ដ៏មានប្រយោជន៍ ពីអ្នកដើរតួជាច្រើន ។ ឯកសារពិភាក្សា នេះ មានគោលបំណងបង្កើនការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធនានា អំពីសេចក្តីព្រាង HSAP ។ យើងពិនិត្យមើលវិធានរបស់ HSAF សម្រាប់ធានានិរន្តរភាព និងប្រៀបធៀបវិធាននេះ ជាមួយក្របខ័ណ្ឌរបស់គណៈកម្មការពិភពលោកស្តីពីទំនប់ (WCD) ។ យើងសង្កត់ធ្ងន់ លើប្រការនានានៅក្នុងសេចក្តីព្រាងពិធីសារវិភាគវាយតំលៃអំពីនិរន្តរភាពនៃថាមពលវារីអគ្គិសនី ដែលគួរតែមានការគិតគូរ និង ការពិភាក្សាគ្នាជាបន្ថែមទៀត ។

# ប្រវត្តិដើម

ក្របខ័ណ្ឌមួយដែលរៀបរៀងឡើងដោយគណៈកម្មការពិភពលោកស្តីពីទំនប់ (WCD) អាចជាក្របខ័ណ្ឌ នៃការធ្វើសេចក្តីសម្រេច សម្រាប់គម្រោងទឹក និងថាមពល ដែលមានលក្ខណៈទូលំទូលាយ ប្រកបដោយសារៈសំខាន់ និងមហិច្ឆិតាបំផុតសម្រាប់គម្រោងទឹក និងថាមពល ។ ដើម្បីស្វែងយល់អំពីវិធានរបស់ HSAF និងការពាក់ព័ន្ធនៃវិធាននេះ គេគួរតែពិនិត្យមើល WCD ជាមុន ។

WCD គឺជាដំណើរការនៃការចូលរួមពហុអ្នកពាក់ព័ន្ធដ៏ធំមួយ ដែលបានអនុវត្តនៅក្នុងឆ្នាំ១៩៩៨-២០០០ ។ WCD បានពិនិត្យមើលប្រសិទ្ធិភាពនៃទំនប់ខ្នាតធំ នៅក្នុងការសម្រេចគោលដៅអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

WCD មានសមាសភាពពីក្រុមអ្នកជំនាញការ ចំនួន ១២ រូប ជាតំណាងមកពីឧស្សាហកម្មវារីអគ្គិសនី សង្គមស៊ីវិល ប្រជាពលរដ្ឋរងគ្រោះ រដ្ឋាភិបាល និងគ្រឹះស្ថានស្រាវជ្រាវ ។ សមាជិកគណកម្មការបានទទួលការគាំទ្រពីលេខាធិការដ្ឋានអាជីពមួយ ដែលមានបុគ្គលិកចំនួន ១០ រូប និង ធ្វើសេចក្តីរាយការណ៍អំពីការរីកចម្រើនរបស់ពួកគេ ទៅវេទិកានៃអ្នកពាក់ព័ន្ធ ដែលមានសមាសភាពមកពីអង្គការចំនួន ៦៨ (ក្នុងនោះក៏មាន IHA ផងដែរ) ។

គណៈកម្មការWCD បានសិក្សាស៊ីជម្រៅលើទំនប់ចំនួនប្រាំពីរ និងប្រទេសអ្នកសាងសង់ទំនប់ចំនួនបី និងបានបោះពុម្ពផ្សាយឯកសារបច្ចេកទេសចំនួន ១៣០ ។ WCD បានចាត់ចែងឱ្យមានការពិគ្រោះយោបល់ជាច្រើននៅក្នុងតំបន់នានាលើពិភពលោក ដោយមានអ្នកចូលរួមចំនួន ១៤០០ នាក់ និងបានទទួលយោបល់ចំនួន ៩៥០ ពីអ្នកជំនាញការ និងសាធារណជន (World Commission on Dams 2000) ។ រហូតដល់ចុងឆ្នាំ ២០០០ គណៈកម្មការ WCD បានរៀបចំឱ្យមានក្របខ័ណសំខាន់បំផុតមួយលើពិភពលោក សម្រាប់ការធ្វើសេចក្តីសម្រេច លើគម្រោងទឹក និងថាមពល ដែលគាំទ្រដោយមូលដ្ឋានចំណេះដឹង ។

ក្របខ័ណ្ឌនេះបានប្រើប្រាស់ការរកឃើញរបស់គណៈកម្មការនេះទាក់ទងនឹងប្រសិទ្ធិភាពនៃទំនប់ខ្នាតធំ ។ របកគំហើញដ៏ខាន់មួយគឺជាញឹកញាប់បំផុត ទំនប់ខ្នាតធំមិនបានធ្វើឱ្យមានការបែងចែកផលចំណេញ និងផលប៉ះពាល់ដោយយុត្តិធម៌ឡើយ ។ ក្របខ័ណ្ឌថ្មីរបស់គណៈកម្មការ WCD សម្រាប់ការធ្វើសេចក្តីសម្រេចបានផ្អែកលើវិធានមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដែលក្នុងនោះសិទ្ធិរបស់ប្រជាជននិង ពលរដ្ឋរងគ្រោះ ត្រូវបានទទួលការយកចិត្តទុកដាក់ជាសំខាន់ ។ ប្រការនេះ ស្របទៅនឹងសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍ នៅក្នុងពេលនោះផងដែរ (Dubash et al. 2001: 100) ។ ដោយគោរពតាមទិសដៅអភិវឌ្ឍន៍ទាំងប្រាំពីរ គណៈកម្មការ WCD បានអះអាងថា សិទ្ធិរបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍ ក៏ដូចជាសិទ្ធិជាមូលដ្ឋានរបស់ពួកគេ គួរបានទទួលកិច្ចការពារផងដែរ ។ "អាទិភាពជាយុទ្ធសាស្ត្រ" ទាំងនេះរួមមាន ការកើនឡើង នូវការទទួលយកជាសាធារណៈ ការវិភាគវាយតំលៃដោយទូលំទូលាយលើជម្រើសនានា ការទ្រទ្រង់ដល់ការចិញ្ចឹមជីវិត និង ការចែកផលគ្នា ដោយនិរន្តរភាព (សូមអាន រូបទី១) ។ ដើម្បីជួយអនុវត្តអាទិភាពជាយុទ្ធសាស្ត្រទាំងប្រាំពីរគណៈកម្មការ WCD បានចែងនូវ "គោលការណ៍ណែនាំសម្រាប់ការអនុវត្តល្អប្រពៃ" លំអិតថែមទៀតចំនួន ២៦ ។

## រូបទី១ ក្របខ័ណ្ឌរបស់ WCD សម្រាប់ការធ្វើសេចក្តីសម្រេច

### ១.បទដ្ឋានសកល
- ២. សេចក្តីថ្លែងការណ៍សកល អំពីសិទ្ធិមនុស្ស (1948)
- ៣. សិទ្ធិក្នុងការអភិវឌ្ឍ (1948)
- ៤.សេចក្តីថ្លែងការណ៍ក្រុងរីយ៉ូ ស្តីពីបរិស្ថាន និងអភិវឌ្ឍន៍ (1992)

### ៥.គុណតម្លៃស្នូល
- ៦.ការធ្វើសេចក្តីសម្រេច តាមបែបផែននៃការចូលរួម
- ៧.សមធម៌
- ៨. ភាពផ្តល់ផលទាន់ពេលវេលា
- ៩.គណនេយ្យភាព
- ១០.និរន្តរភាព

### ១១.ចំណុចសំខាន់ៗនៃការសម្រេច
១២.កំណត់តម្រូវការចាំបាច់ → ១៣.ការរើសយកជម្រើសជំនួស → ១៤.ការរៀបចំគម្រោង → ១៥.ការអនុវត្តគម្រោង → ១៦.ប្រតិបត្តិការគម្រោង

### ១៧. អាទិភាពជាយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំអំពីការអនុវត្តទម្លាប់ល្អ

**១៨.ការទទួលយកកាន់ច្រើនពីសាធារណជន**
- ១៩.ការវិភាគអំពីអ្នកពាក់ព័ន្ធ
- ២០.ការចរចាអំពីដំណើរការធ្វើសេចក្តីសម្រេច
- ២១. ការឯកភាពដោយសេរី និងដោយយល់ដឹងជាមុន

**២២.ការវិភាគវាយតំលៃលំអិតអំពីជម្រើសនានា**
- ២៣. ប៉ាន់ប្រមាណជាយុទ្ធសាស្ត្រនូវផលប៉ះ ពាល់ខាងផ្នែកបរិស្ថាន សង្គម សុខភាព និងបេតិកភណ្ឌវប្បធម៌
- ២៤. វិភាគវាយតំលៃផលប៉ះពាល់ពីគម្រោង
- ២៥.ការវិភាគដែលផ្អែក លើពហុលក្ខណៈវិនិច្ឆ័យ
- ២៦.ការវិភាគវាយតំលៃវដ្តទាំងមូលនៃគម្រោង
- ២៧.ការបំភាយឧស្ម័នផ្ទះកញ្ចក់
- ២៨.ការវិភាគលើរបាយការនៃគម្រោង
- ២៩.ការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន
- ៣០.កែលម្អការវិភាគវាយតំលៃហានិភ័យសេដ្ឋកិច្ច

**៣១. ដោះស្រាយទំនប់ដែលមានស្រាប់**
- ៣២.ធានាថាបទបញ្ជាអនុវត្តឆ្លុះបញ្ចាំងពីកង្វល់ខាងសង្គម និងបរិស្ថាន
- ៣៣.កែលម្អប្រតិបត្តិការនៃអាងទឹក

**៣៤. ទ្រទ្រង់និរន្តរភាពនៃទន្លេនិងរបរចិញ្ចឹមជីវិត**
- ៣៥.ការអង្កេតស្ថានភាពគោលនៃប្រព័ន្ធអេកូឡូស៊ី
- ៣៦.ការប៉ាន់ប្រមាណលំហូរបរិស្ថាន
- ៣៧.ការរក្សាផលិតភាពជលផល

**៣៨.ទទួលស្គាល់សិទ្ធិ ទទួលផល និងការចែកផល**
- ៣៩.លក្ខខណ្ឌគោលខាងសង្គម
- ៤០.ការវិភាគហានិ ភ័យនៃភាពក្រ
- ៤១. អនុវត្តផែនការកាត់បន្ថយផលប៉ះពាល់ ការតាំងលំនៅឡើងវិញ និងផែនការអភិវឌ្ឍន៍
- ៤២.យន្តការចែកផលពីគម្រោង

**៤៣.ធានាឱ្យមានការអនុវត្តតាម**
- ៤៤.ផែនការស្តីពីការប្រតិបត្តិតាម
- ៤៥.ក្រុមឯករាជ្យដើម្បីពិនិត្យកិច្ចការសង្គម និងបរិស្ថាន
- ៤៦.ប្រាក់ធានាលើការអនុវត្ត
- ៤៧.មូលនិធិត្រាស់
- ៤៨.កត្តិការសញ្ញាអំពីសុចរិតភាព

**៤៩.ចែករំលែកការប្រើប្រាស់ទន្លេដើម្បីសន្តិភាពការអភិវឌ្ឍ និងសន្តិសុខ**
- ៥០.នីតិវិធីសម្រាប់ការប្រើប្រាស់ទន្លេរួមគ្នា

**ប្រភព៖** Dore et al. (2004)

គេអាចអះអាងថា ក្របខ័ណ្ឌរបស់ WCD បានក្លាយជាក្របខ័ណ្ឌលេចធ្លោបំផុតមួយលើពិភពលោកសម្រាប់វិភាគវាយតំលៃលើនិរន្តរភាពនៃគម្រោងសាងសង់ទំនប់ខ្នាតធំ ។ រាល់គម្រោងសាងសង់ទំនប់ខ្នាតធំ ដែលចង់លក់ឥណទានកាបូននៅក្នុងប្រព័ន្ធពាណិជ្ជកម្មកាបូនរបស់សហភាពអឺរ៉ុប ត្រូវតែគោរពតាមក្របខ័ណ្ឌរបស់គណៈកម្មការ WCD (International Rivers 2008) ។ ធនាគារពិភពលោក ដែលជាទីភ្នាក់ងារលក់ឥណទានកាបូន និង IHA សុទ្ធតែគាំទ្រអាទិភាពជាយុទ្ធសាស្ត្ររបស់WCD ប៉ុន្តែប្រកាន់ជំហរខុសៗគ្នា ចំពោះគោលការណ៍ណែនាំជាក់លាក់របស់ WCD ។

ការរិះគន់ដ៏សំខាន់មួយចំពោះ WCD គឺថា ក្របខ័ណ្ឌរបស់ WCD អាចធ្វើឱ្យប្រទេសនានាចំណាយពេលច្រើន និងជួបការលំបាកនៅក្នុងការសាងសង់ទំនប់ ដែលចាំបាច់សាងសង់ជាបន្ទាន់ណាមួយ ។ ឧទាហរណ៍ WCD អំពាវនាវអោយមាន ការទទួលយករបស់សាធារណៈដែលអាចបង្ហាញឱ្យឃើញលើរាល់ការសម្រេចសំខាន់ៗ ទទួលបានតាមរយៈការចរចាដោយយុត្តិធម៌ និងតាមបែបនៃការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់តែប៉ុណ្ណោះ ។ WCD ក៏អំពាវនាវឱ្យមាន "ការឯកភាពមតិដោយសេរី និងដោយការយល់ដឹងជាមុន" (FPIC) ផងដែរ ពីសំណាក់ជនជាតិដើម និងកុលសម្ព័ន្ធនានា ដែលធ្វើឡើងតាមរយៈស្ថាប័នតំណាងផ្លូវការ និងមិនផ្លូវការរបស់ក្រុមជនជាតិទាំងនោះ (WCD 2000: 219-220) ។ ក្រុមអ្នកអភិវឌ្ឍន៍ទំនប់ចោទថា អនុសាសន៍នេះផ្តល់ទៅឱ្យក្រុមមនុស្សភាគតិច នូវសិទ្ធិជំទាស់វេតូ លើគម្រោងអភិវឌ្ឍន៍ ។ ផ្ទុយទៅវិញ ក្រុមជនរងគ្រោះ និងអង្គការអភិវឌ្ឍន៍ NGOs គាំទ្រ FPIC ។ ពួកគេមើលឃើញថា FPIC គឺជាដំណើរការកំពុងអនុវត្តមួយនៃការបង្កើត និងធានាឱ្យមានការឯកភាពមតិរវាងអ្នកឧបត្ថម្ភ និងតំណាងក្រុមជនរងគ្រោះ ពីអាងទឹក ឬ ទំនប់ទឹកទាំងអស់ដោយមិនមែនសំរាប់តែក្រុមជនជាតិដើមប៉ុណ្ណោះទេ (Dubash et al. 2001; Simon 2009) ។

ជាសង្ខេប WCD បានផ្តល់នូវបទដ្ឋានស្តង់ដារកម្រិតខ្ពស់មួយសម្រាប់ការពិនិត្យមើលឡើងវិញ នូវទំនប់ដែលមានស្រាប់ និងទំនប់ដែល គ្រោងនឹងសាងសង់ ព្រមទាំងដើម្បីដោះស្រាយកិច្ចការដែលនៅពុំទាន់ដាច់ស្រេច ឬដែលបន្សល់ទុកពីគម្រោង ដែលមានស្រាប់ ។ ប្រសិនបើយកមកអនុវត្តអនុសាសន៍របស់ WCD អាចធ្វើអោយសេចក្តីសំរេចចិត្តយឺតយ៉ាវ ដោយសារអនុសាសន៍ទាំងនោះទាមទារឱ្យមានការ វិភាគវាយតំលៃលើគម្រោងសាងសង់ទំនប់ខ្នាតធំដោយផ្អែកលើទស្សនៈវិស័យខុសៗគ្នា ។ WCD អះអាងថា ប្រជាពលរដ្ឋសាមញ្ញ និងជនរងគ្រោះមានសិទ្ធិ ក្នុងការជះឥទ្ធិពលដោយផ្ទាល់ និងយ៉ាងសកម្ម មកលើការសម្រេចនានាអំពីថាមពល ទឹក និងទំនប់ ។ អនុសាសន៍នេះ ពិតជាទាមទារឱ្យមានការផ្លាស់ប្តូរយ៉ាងច្រើន លើទំលាប់នៃការកសាងផែនការនិងការអនុម័ត ដែលមានក្នុងពេលបច្ចុប្បន្ន ។ នៅក្នុងប្រទេសភាគច្រើនការទទួលយក នូវការកែប្រែបែបនេះ ទំនងជាត្រូវទាមទារពេលវេលាដ៏វែងមួយ ។ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរទាំងនេះ គេត្រូវធ្វើការឆ្លុះបញ្ចាំង ការពិភាក្សា និងការសន្ទនាជាបន្តបន្ទាប់រវាងរដ្ឋ វិស័យឯកជន និង ក្រុមសង្គមស៊ីវិលខុសៗគ្នា ។

# វិធានឆ្ពោះទៅរកនិរន្តរភាពប្រកាន់យកដោយក្រុមឧស្សាហកម្ម

វិធានរបស់ IHA ចាប់ផ្តើមដោយការជឿថា គម្រោងវារីអគ្គិសនីគ្រប់ខ្នាតទាំងអស់ ផ្តល់ជូនពិភពលោក នូវថាមពល ដែលមានប្រសិទ្ធិភាពខ្ពស់បំផុត និង ដែលគ្មានការបំពុល (International Hydropower Association 2003)។ វិធានដែលនាំមុខដោយឧស្សាហកម្ម មានទិដ្ឋភាពជាច្រើនស្រដៀងគ្នាទៅនឹងវិធានរបស់ WCD ដែរ។ IHA គាំទ្រដល់គុណតម្លៃស្នូល និងគោលការណ៍ជាយុទ្ធសាស្ត្ររបស់ WCD ។ មានន័យថា IHA គាំទ្រ "គោលការណ៍នៃដំណើរការកសាងផែនការ ក្នុងលក្ខណៈសមាហរណកម្ម ការវិភាគវាយតំលៃជម្រើសនានាដោយលំអិត ការអភិវឌ្ឍន៍សមស្របបំផុត និងការគ្រប់គ្រងប្រកប ដោយការទទួលខុសត្រូវ ក៏ដូចជាការគិតគូរអំពីសមធម៌សង្គមនៅគ្រប់ដំណាក់កាលទាំងអស់នៃការអនុវត្តគម្រោងផងដែរ តាមរយៈកម្មវិធី ដែលគ្រោងទុកជាមុន សម្រាប់ការពិគ្រោះយោបល់ជាមួយសហគមន៍" (IHA 2003: 12, 94)។




គោលគំនិតអំពីការកសាងផែនការរបស់ IHA គឺជាការរួមផ្សំរវាងសុទិដ្ឋិនិយមនិងភាពជាក់ស្តែងនៅក្នុងការសរសេរគម្រោង។ សុទិដ្ឋិនិយម នៅទីនេះមានន័យថា គេជឿថា គេអាចកំណត់ និង សាងសង់គម្រោងល្អៗសម្រាប់ផលិតថាមពល និង ក៏អាចកំណត់និងដោះស្រាយបញ្ហាស្មុគស្មាញខាងបរិស្ថាននិងសង្គមបានជាទីពេញចិត្តផងដែរ។ ភាពជាក់ស្តែង (ភាពប្រាកដនិយម) សំដៅលើគំនិតក្នុងការសំរេចបាននូវទម្លាប់អនុវត្តដែលល្អ ប៉ុន្តែមិនចាំបាច់ឱ្យសុក្រឹត្យដាច់ខាតនោះឡើយ (IHA 2003: 95)។

# តើចង់ឱ្យពិធីសារនៃការវិភាគវាយតំលៃអំពីនិរន្តរភាពនៃវារីអគ្គិសនីមាននាទីយ៉ាងដូចម្តេច?

HSAP មានបំណងផ្តល់ជាគោលការណ៍ណែនាំជាក់ស្តែងមួយឈុត សម្រាប់ការធ្វើសវនកម្មគម្រោងថាមពលវារីអគ្គិសនី ពោលគឺ ទាំងគម្រោងដែលមានស្រាប់ និងដែលបានគ្រោងថ្មី នៅក្នុងពេលវេលាជាកំណត់ដែលជាការឆ្លើយតបជាពិសេសទៅនឹងតម្រូវការចាំបាច់ របស់គ្រឹះស្ថានហិរញ្ញវត្ថុឯកជន វិនិយោគិន និងប្រតិបត្តិករ ។ ទោះជាយ៉ាងណាក៏ដោយ HSAF ក៏សង្ឃឹមថា សេចក្តីព្រាងពិធីសារឆ្នាំ ២០០៩ របស់ខ្លួន នឹងត្រូវបានយកទៅអនុវត្តសាកល្បងពីសំណាក់ក្រុមនានាជាច្រើន ដែលរួមទាំង សង្គមស៊ីវិល និងបន្ទាប់មក បានទទួលការគាំទ្រពីសង្គមស៊ីវិលផងដែរ ។

HSAP ចែកជាបួនផ្នែក (International Hydropower Association 2009b) ។ ក្របខ័ណ្ឌនេះ ចែងអំពី ដំណាក់កាលខុសៗគ្នានៃវដ្តគម្រោង ដែលចាប់ផ្តើមពី (១) *ការវិភាគវាយតំលៃជាយុទ្ធសាស្ត្រ* លើគម្រោងសម្រាប់ផ្តល់ថាមពលនិងសេវាកម្មទឹក (២) *ការរៀបចំគម្រោងផលិតវារីអគ្គិសនី* (ពោលគឺ ការសិក្សា និងផែនការនានា ដែលធ្វើឡើងនៅមុនចុះកិច្ចសន្យាសាងសង់) (៣) *ការអនុវត្ត គម្រោងវារីអគ្គិសនី* និង (៤) *ប្រតិបត្តិការគម្រោងវារីអគ្គិសនី*។

ផ្នែកនីមួយៗ ចែងអំពី ទិដ្ឋភាពមួយចំនួន (សេដ្ឋកិច្ច សង្គម បរិស្ថាននយោបាយ) ដែលអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ដាក់ពិន្ទុលើគម្រោងវារីអគ្គិសនី ឬ កិច្ចផ្តួចផ្តើមអភិវឌ្ឍន៍ ពីទាបទៅខ្ពស់ ដោយផ្អែកលើការអនុវត្តជាក់ស្តែង (សូមអានរូបទី២ និង តារាងទី១) ។ ផ្នែកនីមួយៗចែងជាបន្ថែមលើផ្នែកខាងដើម នៅក្នុង HSAP ប៉ុន្តែផ្នែកនីមួយៗក៏ត្រូវបានរៀបចំឡើង ដើម្បីធ្វើការវិភាគវាយតំលៃ ដាច់ដោយឡែកក៏បាន ។

**រូបទី ២: រចនាសម្ព័ន្ធនៃពិធីសារវិភាគវាយតំលៃអំពីក្រម្រិតនិរន្តរភាព**




**ប្រភព:** IHA (2009b)

**តារាងទី១ សេចក្តីព្រាងពិធីសារវិភាគវាយតំលៃលើនិរន្តរភាពនៃវារីអគ្គិសនី ៈ សេចក្តីសង្ខេបលក្ខណៈវិនិច្ឆ័យ និង សូចនាករសម្រាប់ការវិភាគវាយតំលៃ**

| ផ្នែក/គោលបំណង | ឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យ និងសំណួរពាក់ព័ន្ធសំខាន់ៗ |
|---|---|
| **(I) ការវិភាគវាយតំលៃជាយុទ្ធសាស្ត្រ**<br>វិភាគវាយតំលៃមូលដ្ឋានគ្រឹះជាយុទ្ធសាស្ត្រ សម្រាប់គម្រោងវារីអគ្គិសនី ដែលត្រូវបានស្នើឡើង | លក្ខណៈវិនិច្ឆ័យ (ទិដ្ឋភាព) ទាំងដប់ ជារួមមាន ៈ<br>**បង្ហាញពីតម្រូវការចាំបាច់ច្បាស់លាស់**–តើសំណើគម្រោងនោះ មានអំណះអំណាងសមជាប្រភពអគ្គិសនី និង/ឬ សេវាកម្មទឹក ជាងគេដែរឬទេ? នៅពេលប្រមាណអំពីតម្រូវការអគ្គិសនី និងសេវាកម្មទឹក តើដំណើរការប៉ាន់ ប្រមាណនោះមានគុណភាពបែបណាដែរ? នៅពេលកំណត់គោលដៅនៃការអភិវឌ្ឍន៍ថាមពល និងទឹក តើដំណើរ ការពិគ្រោះយោបល់នោះមានគុណភាពបែបណាដែរ?<br>**ការវិភាគវាយតំលៃលើជម្រើស**–តើវាគ្របដណ្តប់រាល់វិធាននានានៃការកសាងផែនការទាំងមូលរួមទាំងការអភិវាបានកម្រិតណា ដល់ការវិភាគវាយតំលៃអំពីជម្រើសនោះ?<br>**គោលនយោបាយ និងផែនការប្រចាំតំបន់ និងថ្នាក់ជាតិ**–តើផែនការនានាដែលមានស្រាប់ខាងផ្នែកថាមពល ទឹក ការអភិរក្ស និងការអភិវឌ្ឍសេដ្ឋកិច្ច មានគុណភាពបែបណា? តើផែនការទាំងនោះផ្តល់ជាការណែនាំបានល្អ កម្រិតណា សម្រាប់ការកសាងផែនការគម្រោងវារីអគ្គិសនី? តើសំណើគម្រោងនោះមានសង្គតិភាពសមស្របកម្រិតណា ជាមួយនឹងផែនការនានាខាងលើទាំងនេះ?<br>**ហានិភ័យផ្នែកនយោបាយ**–តើការវិភាគអំពីហានិភ័យខាងនយោបាយ បានធ្វើឡើងបានទូលំទូលាយកម្រិតណា? តើហានិភ័យខាងនយោបាយ មានកម្រិតណា? (ឧទាហរណ៍អំពីហានិភ័យខាងនយោបាយរួមមាន ៈ ហានិភ័យ នៃការជ្រៀតជ្រែកខាងនយោបាយ អំពើពុករលួយ ការរឹបអូសដកហូតសិទ្ធិពីសំណាក់ក្រុមហ៊ុនតាមផ្លូវច្បាប់ បញ្ហា នានាដែលទាក់ទងនឹងការប្តូររូបិយប័ណ្ណ និងអំពើហឹង្សានយោបាយ)។<br>**សមត្ថភាពខាងស្ថាប័ន**–តើមានផែនការគ្រប់គ្រងនានា សម្រាប់ដោះស្រាយការខ្វះខាតខាងសមត្ថភាពនៃវិស័យ សាធារណៈដែរឬទេ? តើការខ្វះខាតបែបនោះ អាចគ្រប់គ្រងបានក្នុងកម្រិតណា?<br>*គេអាចប្រើប្រាស់លទ្ធផលនៃការវិភាគទាំងនេះ សម្រាប់ជាមូលដ្ឋានក្នុងការសម្រេចចិត្តថា តើគួរធ្វើវិនិយោគ (ឬមិនវិនិយោគ) នៅក្នុងការរៀបចំគម្រោងថ្មីមួយ ។ ចំពោះគម្រោងដែលមានស្រាប់ គេអាចប្រើប្រាស់លទ្ធផលទាំងនេះ ជាមូលដ្ឋាន សម្រាប់ការធ្វើសេចក្តីសម្រេចសំខាន់ៗ ដែលទាក់ទងនឹងកំណែលម្អ ឬ បញ្ឈប់ដំណើរការគម្រោង ។* |
| **(II) ការរៀបចំគម្រោង**<br>វិភាគវាយ តំលៃអំពីគុណភាពនៃ ការស៊ើបអង្កេតលើគម្រោងផែនការ និងទម្រង់ប្លង់នានា | **លក្ខណៈវិនិច្ឆ័យ(ទិដ្ឋភាព)**–ទាំង ២៨ រួមមាន កម្រិតនៃការអាចទទួលជោគជ័យខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការវាយតម្លៃហេតុ ប៉ះពាល់បរិស្ថាន (EIA) ការវាយតម្លៃហេតុប៉ះពាល់ខាងសង្គម ការបែងចែកផល សហគមន៍ដែលរងគ្រោះដោយសារ គម្រោង ការតាំងទីលំនៅឡើងវិញ ក្រុមជនជាតិដើម និង កុលសម្ព័ន្ធ ជនជាតិភាគតិច បញ្ហាប៉ះពាល់ពីប្រទេសមួយទៅលើប្រទេសមួយ លំហូរបរិស្ថាន និងនិរន្តរភាពនៅ តំបន់ខ្សែទឹកខាងក្រោម ការអនុម័តលើបទប្បញ្ញត្តិនានា អភិបាលកិច្ចសារជីវកម្ម។<br>លក្ខណៈវិនិច្ឆ័យនីមួយៗ មានភ្ជាប់ជាមួយនូវសូចនាករមួយឈុត<br>(សំណួរសម្រាប់ការវិភាគវាយតំលៃ)។ |

| ផ្នែក/គោលបំណង | ឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យ និងសំណួរពាក់ព័ន្ធសំខាន់ៗ |
|---|---|
| | ផ្នែក II ទាមទារឱ្យមានការវិភាគវាយតំលៃអំពីតម្រូវការចាំបាច់ ដែលបង្ហាញឱ្យឃើញច្បាស់ជាក់លាក់ ( បានវិភាគវាយតំលៃនៅក្នុងផ្នែក I ) ។<br>*គេអាចប្រើប្រាស់លទ្ធផលវិភាគទាំងនេះ ជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចអនុម័តលើគម្រោង និងផ្តល់ ( ឬមិនផ្តល់ ) កិច្ចសន្យាសាងសង់ ។* |
| **(III) ការអនុវត្តគម្រោង**<br>វិភាគវាយតំលៃ គុណភាព នៃការសាងសង់ និង កម្មវិធីគ្រប់គ្រង ផ្នែកសង្គម និងបរិស្ថាន | **លក្ខណៈវិនិច្ឆ័យ (ទិដ្ឋភាព) ចំនួន២៦**–ដែលក្នុងនោះ ២៤ គឺបានលក្ខណៈវិនិច្ឆ័យពីផ្នែកទី II (ដែលអនុញ្ញាតឱ្យ មានការវិភាគវាយតំលៃឡើងវិញ) ។ លក្ខណៈវិនិច្ឆ័យនីមួយៗ ភ្ជាប់ជាមួយនូវសូចនាករដោយឡែកៗរបស់ខ្លួន ។<br>*គេអាចប្រើប្រាស់លទ្ធផលវិភាគទាំងនេះ សម្រាប់ការសម្រេច ដើម្បីចាប់ផ្តើម ( ឬមិនចាប់ផ្តើម ) ដំណើរការសមទ្ធិផល ។* |
| **(IV) ប្រតិបត្តិការគម្រោង**<br>វិភាគវាយតំលៃអំពីគុណភាព នៃគម្រោងដែលកំពុងប្រតិបត្តិការ | **លក្ខណៈវិនិច្ឆ័យ (ទិដ្ឋភាព) ចំនួន ២៣**–ដែលក្នុងនោះ ២១ លក្ខណៈវិនិច្ឆ័យបានពីផ្នែកទី III ឬទី II (ដែលអនុញ្ញាត ឱ្យមានការវិភាគវាយតំលៃឡើងវិញ) ។<br>លក្ខណៈវិនិច្ឆ័យនីមួយៗភ្ជាប់ជាមួយនូវសូចនាករដោយឡែករបស់ខ្លួន ។<br>*គេអាចប្រើប្រាស់លទ្ធផលទាំងនេះ សម្រាប់ការសម្រេច ដែលអនុញ្ញាតឱ្យឬកែសម្រួលប្រតិបត្តិការដែលមានស្រាប់ ។* |

ប្រភព: ផ្អែកតាម HSAF (2009a) សំគាល់: សំណួរនៅក្នុងតារាងនេះ គឺជាការបកស្រាយរបស់អ្នកនិពន្ធ ដោយផ្អែកលើអត្ថន័យដែលបានពីសូចនាករនានា ។ HSAF ចាត់ទុកលក្ខណៈវិនិច្ឆ័យនានាថាជា "ទិដ្ឋភាព" និងសូចនាករ ថាជា "សញ្ញាសំគាល់" ។

គោលដៅរបស់ HSAF គឺបង្កើតបច្ចេកទេសសម្រាប់ការវិភាគវាយតំលៃជាលក្ខណៈប្រព័ន្ធ និងគ្មានលំអៀង លើការប្រព្រឹតទៅ និង និរន្តរភាព នៃគម្រោងវារីអគ្គិសន ។ ជាគោលគំនិត គោលការណ៍ណែនាំនេះ គួរផ្តល់នូវរចនាសម្ព័ន្ធគ្រប់គ្រាន់សំរាប់បំពេញតួនាទីមួយ ដែលអាចជួយដល់អ្នកធ្វើការវិភាគវាយតំលៃ បើទោះអ្នកនោះជាអ្នកអភិវឌ្ឍន៍វារីអគ្គិសនី អង្គការមិនមែនរដ្ឋាភិបាលដែល មានចំណាប់អារម្មណ៍លើផលប៉ះពាល់ដល់មូលដ្ឋាន ឬ ក៏អង្គការឯករាជ្យណាមួយ ក្នុងការឈានទៅដល់ សន្និដ្ឋានប្រហាក់ប្រហែលគ្នា ។

## ស្ថានភាព

នៅឆ្នាំ ២០០៩ វេទិកានេះបានបង្ហាញជូននូវរចនាសម្ព័ន្ធជាមូលដ្ឋានមួយ និងខ្លឹមសារគោល នៃសេចក្តីព្រាងពិធីសារនេះ នៅក្នុង "ឯកសារសមាសភាគសំខាន់ៗ" មួយ ដែលជាឯកសារកំណត់អំពីក្របខណ្ឌព្រំដែនរបស់ពិធីសារនេះ (IHA 2009b) ។ បន្ទាប់មក វេទិកានេះបានធ្វើការពិគ្រោះជាសាធារណៈលើកដំបូងមួយ នៅខែមករា-មីនាឆ្នាំ២០០៩ ដើម្បីបង្កើនការយល់ដឹងអំពីដំណើរការរបស់ខ្លួន និង ដើម្បីប្រមូលមតិយោបល់ លើឯកសារសមាសភាគសំខាន់ៗនោះ ។ ការពិគ្រោះយោបល់នោះ បានប្រើប្រាស់បញ្ជីសំណួរស្ទង់មតិតាមប្រព័ន្ធវេបសាយ និង ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ ។ អ្នកដើរតួសំខាន់ៗ ទាំងនៅខាងក្នុង និងមកពីខាងក្រៅ ឧស្សាហកម្មវារីអគ្គិសនីបានការផ្តល់យោបល់ជាច្រើនដល់ឯកសារសមាសភាគសំខាន់ៗនោះ (សូមអាន ARUP2009) ។

នៅខែសីហា ឆ្នាំ២០០៩ HSAF បានចេញផ្សាយពិធីសារសំរាប់ការវិភាគវាយតំលៃអំពីនិរន្តរភាពថាមពលវារីអគ្គិសនី(សូមអានHSAF 2009a) ។វេទិកានេះបានប្រកាសផ្សាយអំពីការពិគ្រោះយោបល់ជាសាធារណៈជុំទីពីរ ( តាមអ៊ិនធឺណិត និងជួបផ្ទាល់ ) និងសាកល្បងអនុវត្តនៅក្នុងអំឡុងខែកញ្ញា-វិច្ឆិកា ឆ្នាំ២០០៩ ។ជុំទីពីរនៃការពិគ្រោះយោបល់ ផ្តោតលើខ្លឹមសារ និងកម្រិតដែលអាចអនុវត្តជាក់ស្តែង នៃ សេចក្តីព្រាងពិធីសារចុះខែ សីហា ឆ្នាំ២០០៩ ។

# កិច្ចការគន្លឹះនានាសម្រាប់តំបន់មេគង្គ

នៅពេលនិយាយថា "តំបន់មេគង្គ" យើងសំដៅលើភូមិសាស្ត្រនយោបាយ ដែលរួមមានប្រទេស កម្ពុជា ឡាវ ភូមា ថៃ វៀតណាម និងខេត្តយូណាននិងក្វាងស៊ីនៃប្រទេសចិន ។តាមរយៈការកំណត់របៀបនេះ តំបន់នេះមានវិសាលភាព បីដងធំជាងអាងទន្លេមេគង្គទៅទៀត និង ជាកន្លែងដែលប្រជាជន ៣០០លាននាក់រស់នៅ (Lebel et al. 2007) ។

មុនមានការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០០៨ តំបន់នេះបានឆ្លងកាត់នូវដំណាក់កាលរីកដុះដាលខ្លាំង លើការជម្រុញឱ្យមានគម្រោងអភិវឌ្ឍន៍ខ្នាតធំ លើផ្នែកវារីអគ្គិសនី និងធនធានទឹក ។ជាក់ស្តែង រដ្ឋាភិបាលនៃប្រទេសឡាវមានទំនប់ចំនួន៨ដែលកំពុងស្ថិតក្រោមការសាងសង់និង១៦នៅចុងដំណាក់កាលកសាងផែនការ ។ រដ្ឋាភិបាលនៃប្រទេសនេះ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដំបូង ជាមួយវិនិយោគិន លើគម្រោងថាមពលវារីអគ្គិសនីចំនួន ៥៥ផ្សេងទៀត (MEM 2009) ។

ភាគច្រើននៃការរីកដុះដាលដល់កម្រិតកំពូលក្នុងតំបន់នេះគឺជាលទ្ធផលនៃ (១) គោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីជម្រុញ ឱ្យមានការលូតលាស់សេដ្ឋកិច្ច តាមរយៈការសាងសង់ទំនប់ និង ការលក់អគ្គិសនី (២) ជំនឿក្នុងចំណោមអ្នកកសាងផែនការថាមពលថា វារីអគ្គិសនី ផ្តល់នូវផលចំណេញជាច្រើនធៀបនឹងអគ្គិសនីដែលបានពីឥន្ធនៈផូស៊ីល (៣) បរិយាកាសខាងផ្នែកច្បាប់ ដែលផ្តល់អាទិភាពដល់ភាពអាចទទួលជោគជ័យផ្នែកពាណិជ្ជកម្ម ខ្ពស់ជាងការបំពេញតួនាទីសង្គម និងបរិស្ថានរបស់គម្រោង (Molle et al. 2009) ។

នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ តំបន់នេះបានឃើញកំណើនចំនួនទំនប់ដែលបានកសាង និងទទួលហិរញ្ញវត្ថុ ឬ ថវិកាបដិភាគពីអ្នកផ្តល់ហិរញ្ញវត្ថុ"ថ្មីៗ"(ពោលគឺតួអង្គដែលមិនមែនជាធនាគារអភិវឌ្ឍន៍ពហុភាគី ដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី) ។ អ្នកផ្តល់ហិរញ្ញប្បទានថ្មីៗធំជាងគេ គឺធនាគាររដ្ឋមកពីប្រទេសចិន ។ ប្រភពហិរញ្ញវត្ថុថ្មីៗផ្សេងទៀត រួមមានក្រុមហ៊ុនរដ្ឋ និង/ឬ ក្រុមហ៊ុនដែលចុះបញ្ជីជាក្រុមហ៊ុនសាធារណៈដែលប្រតិបត្តិការនៅក្នុងតំបន់នេះ ឬ នៅក្នុងប្រទេស នៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ។

ផ្នែកខាងក្រោមនេះគឺផ្តោតលើការពិនិត្យមើលលើសេចក្តីព្រាងពិធីសារនេះ (HSAF 2009; IHA 2009b), យោបល់ដែលទទួលបានពីវេទិកានេះក្រោយការពិគ្រោះយោបល់ជុំទីមួយ (ARUP 2009) ការឆ្លើយតបរបស់ HSAF ទៅនឹងយោបល់ទាំងនោះ (International Hydropower Association 2009a) និងការសម្ភាសអ្នកជំនាញការ ។ យើងប្រៀបធៀបវិធានទូទៅរបស់ HSAF ជាមួយក្របខ័ណ្ឌនិរន្តរភាពផ្សេងៗទៀត និងធ្វើការឆ្លុះបញ្ចាំងអំពីរបៀបណាដែលសំណើ HSAP អាចប្រើការបាននៅក្នុងបរិបទនៃការ ឈានទៅកាន់ការអភិវឌ្ឍន៍អគ្គិសនីយ៉ាងឆាប់រហ័សនៅក្នុងតំបន់មេគង្គផងដែរ ។

ការពិនិត្យសិក្សារបស់យើង បង្ហាញឱ្យឃើញពីបញ្ហាមួយចំនួនដែលគួរតែមានការពិភាក្សាជាបន្ថែម ។

### ចំណងទាក់ទងជាមួយក្របខ័ណ្ឌវិភាគវាយតំលៃផ្សេងទៀត

ចំណងទាក់ទងជាមួយWCD–ក្របខ័ណ្ឌរបស់WCD និងHSAF គាំទ្រដល់គោលគំនិតនៃការកសាងផែនការ គ្រប់គ្រងធនធានទឹក

ដោយឈ្លាសវៃ សម្រាប់រយៈពេលវែង។ ភាពខុសគ្នាជាសំខាន់រវាងក្របខ័ណ្ឌទាំងពីរនេះ គឺ តួនាទីរបស់ប្រជាពលរដ្ឋសាមញ្ញ ដែលមានចែងនៅក្នុងក្របខ័ណ្ឌទាំងនោះ។ WCD មានហេតុផលប្លែកមួយដែលផ្តោតលើសិទ្ធិមនុស្ស ចំណែកសេចក្តីព្រាង HSAP ផ្តោតខ្លាំងលើតួនាទីរបស់រដ្ឋនិងបច្ចេកាធិបតេយ្យ និងច្រើនតែសន្មត់ថាគម្រោងវារីអគ្គិសនីឬគម្រោងនានាសម្រាប់ផលិតវារីអគ្គិសនីត្រូវបានធ្វើអត្តសញ្ញាណរួចមកហើយ។

នៅក្នុងអំឡុងពេលនៃការពិគ្រោះយោបល់ដំបូង អ្នកពាក់ព័ន្ធនានាដែលគាំទ្រវិធានរបស់ WCD បានថ្លែងនៅក្នុងវេទិកានេះថា "ពួកគេបានចូលរួមយ៉ាងច្រើន និងដោយស្មោះត្រង់នៅក្នុង WCD និងពុំចង់ចំណាយពេលវេលាលើដំណើរការណាមួយដែលមិនកសាងបន្ថែមលើដំណើរការដែលមានស្រាប់នេះឡើយ"។ (សូមអាន ARUP 2009: 8-9)។

HSAF បញ្ជាក់ថាខ្លួនពឹងផ្អែកលើគុណតម្លៃស្នូលនិងអាទិភាពជាយុទ្ធសាស្ត្រ ព្រមទាំងគោលការណ៍ និងគោលនយោបាយដែលមានស្រាប់ដទៃទៀតរបស់ WCD (International Hydropower Association 2009a)។ វេទិកានេះបានបោះពុម្ពផ្សាយ ការប្រៀបធៀបអំពីថាតើសេចក្តីសន្និដ្ឋានរបស់ ជឌ ទាក់ទងបែបណាជាមួយឯកសារសមាសភាគសំខាន់ៗរបស់ខ្លួន (HSAF 2009b)។

HSAP ផ្សំដោយកត្តាជាច្រើន ដែលប្រហាក់ប្រហែល នឹងអាទិភាពយុទ្ធសាស្ត្ររបស់ WCDដែរ។ ទោះជាយ៉ាងណាក៏ដោយ ជារួម WCD ពង្រីកសិទ្ធិប្រជាធិបតេយ្យឱ្យកាន់តែទូលាយជាងនៅក្នុងសេចក្តីព្រាង HSAP។ ឧទាហរណ៍ ទាក់ទងនឹងសិទ្ធិរបស់សហគមន៍ ជនរងគ្រោះ ក្នុងការទទួលបានសិទ្ធិ ដែលបានឯកភាពគ្នានៅក្នុងការចរចា សេចក្តីព្រាង HSAP លើកស្នើឱ្យផ្តល់សិទ្ធិនេះទៅសហគមន៍ជន ជាតិដើម ដែលត្រូវតែធ្វើការតាំងទីលំនៅឡើងវិញ និងអ្នកដែលបាត់បង់ដីធ្លីដោយសារគម្រោង (HSAF 2009b)។ ដោយឡែក ក្របខ័ណ្ឌរបស់ WCD អំពាវនាវឱ្យមានការចរចាជាមួយសហគមន៍ទាំងអស់ ដែលការចិញ្ចឹមជីវិតរបស់ខ្លួនត្រូវរងការប៉ះពាល់អវិជ្ជមាន ដើម្បីឈានដល់កិច្ចព្រមព្រៀងគ្នា (WCD 2000: 240)។

ចំណងទាក់ទងជាមួយស្តង់ដារអនុវត្តនៃ សាជីវកម្មហិរញ្ញវត្ថុអន្តរជាត (IFC) – ស្តង់ដារអនុវត្ត របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសាខាវិស័យឯកជនមួយរបស់ធនាគារពិភពលោកផ្តោតលើការវិភាគ និងគ្រប់គ្រងហានិភ័យមកលើវិនិយោគិនហិរញ្ញវត្ថុ។ សេចក្តីព្រាង HSAP ចែងកំរងនៃសូចនាករនានា ដែលមានភាពជាក់លាក់ ទៅតាមវិស័យ (Sector-specific) ខ្លាំងជាង បើប្រៀបធៀបទៅនឹងស្តង់ដាររបស់ IFC (IFC 2006) ឬ គោលការណ៍អេក្វាទ័រ (2006)។ អ្នកឆ្លើយតបមកពីផ្នែកហិរញ្ញវត្ថុ ចង់ឱ្យមានការកែសម្រួល HSAP ស្របតាមស្តង់ដារ IFC។

សេចក្តីព្រាងHSAP បង្ហាញពីចំណងទាក់ទងច្បាស់លាស់ជាមួយស្តង់ដារ IFC សម្រាប់លក្ខណៈវិនិច្ឆ័យនានា ដែលទាក់ទងទៅនឹងជនជាតិដើម និងការតាំងទីលំនៅឡើងវិញ និងការទទួលដីធ្លី។ គេនៅមិនទាន់ដឹងច្បាស់ថា តើបណ្តាគ្រឹះស្ថានហិរញ្ញវត្ថុ នឹងលើកស្នើឱ្យមានការបន្ស៊ីគ្នាឱ្យកាន់តែច្បាស់លាស់ជាងមុនដែរឬទេ។

## វិសាលភាព និងភាពគ្រប់គ្រាន់នៃលក្ខណៈវិនិច្ឆ័យ

អ្នកពាក់ព័ន្ធនានា ដែលបានចូលរួមនៅក្នុងការពិគ្រោះយោបល់ដំណាក់កាលទី១ មិនឯកភាពលើ វិសាលភាពសមស្របរបស់ការវិភាគវាយតំលៃនៅឡើយទេ។ ឧទាហរណ៍ ក្រុមអ្នកអភិវឌ្ឍន៍អាចផ្តោតលើការវិភាគ អំពីហានិភ័យខុសៗគ្នា ចំពោះសំណើគម្រោងមួយ។ អ្នកក្រៅពីក្រុមអ្នកអភិវឌ្ឍន៍ក៏អាចមានចំណាប់អារម្មណ៍លើការវិភាគវាយតំលៃ អំពីគុណភាព នៃគោលនយោបាយថាមពលនៅថ្នាក់ជាតិ និងតំបន់ផងដែរ (ARUP 2009: 14)។

នៅក្នុងការពិភាក្សាជុំដំបូង អ្នកឆ្លើយតបបានពោលថា នៅក្នុងឯកសារសមាសភាគសំខាន់ៗ ការយកចិត្តទុកដាក់ចំពោះ ជនរងគ្រោះ (IHA 2009b) នៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ នៅទីនេះ ពុំទាន់មានចែង អំពីសហគមន៍នៅ តំបន់ខ្សែទឹកខាងក្រោមនៅឡើយទេ។ អ្នកជំនាញការខាងសង្គម បានរិះគន់លើសេចក្តីព្រាងពិធីសារនេះ អំពីការយកចិត្តទុកដាក់ មិនគ្រប់គ្រាន់ចំពោះហានិភ័យនៃការធ្វើឱ្យប្រជាពលរដ្ឋកាន់តែក្រក្រីថែមទៀត។ ពួកគេចង់ឱ្យពិធីសារនេះ ផ្តោតលើការដោះស្រាយ ឱ្យបានត្រឹម

ត្រូវ និង ដោយយុត្តិធម៌ លើកិច្ចការដែលទាក់ទងនឹងការ តាំងទីលំនៅឡើងវិញ លើការទទួលយក និង ការចែកចាយផល។ អ្នកឆ្លើយតបដទៃទៀត ចង់ឱ្យមានឧបករណ៍មួយ សំរាប់វិភាគវាយតំលៃនិរន្តរភាពនៅកម្រិតអាងទន្លេ (ARUP 2009: 13)។ HSAP បានព្យាយាមឆ្លើយតបទៅនឹងបញ្ហាទាំងនេះនៅក្នុង សេចក្តីព្រាង HSAP សំណៅខែ សីហា ឆ្នាំ ២០០៩។

## សារៈសំខាន់នៃការកសាងផែនការយុទ្ធសាស្ត្រ

សេចក្តីព្រាង HSAP ចែកចេញជាបួនផ្នែក ដែលអាចអនុវត្តបាន សំរាប់ដំណាក់កាលខុសៗគ្នានៃវដ្តគម្រោង វារីអគ្គិសនី (រូបទី២)។ ការបែងចែកជាផ្នែកបែបនេះមានសារៈប្រយោជន៍ណាស់ ព្រោះជម្លោះជាច្រើនលើគម្រោងវារីអគ្គិសនី គឺច្រើនជាជម្លោះអំពីភាពមិនគ្រប់គ្រាន់នៃការបញ្ជាក់ហេតុផលជាយុទ្ធសាស្ត្រ ក្នុងការសម្រេចឱ្យមានគម្រោងណាមួយ។ កិច្ចការដែលពាក់ព័ន្ធទៅនឹងការកសាងផែនការយុទ្ធសាស្ត្រ មានចែងច្បាស់នៅក្នុងផ្នែកទី១ នៃសេចក្តីព្រាង HSAP ។ ការកសាងផែនការយុទ្ធសាស្ត្រអាចត្រូវលើកយកមកជជែកដេញដោលគ្នាដោយសារតែហេតុផលមួយចំនួន។ ចំណុចសំរាប់ការជជែកវែកញែកគ្នាអាចមានចាប់ពីតម្រូវការ ដែលត្រូវបង្ហាញឱ្យឃើញច្បាស់លាស់ (ដូចជា តើការផ្គត់ផ្គង់ដែលបានពីសំណើគម្រោងវារីអគ្គិសនីនានាលើសពីតម្រូវការប្រសិទ្ធិភាពសេដ្ឋកិច្ចនៃថាមពលអគ្គិសនី ដែរឬទេ?) រហូតដល់ជម្លោះអំពីថា តើការអភិវឌ្ឍសេដ្ឋកិច្ចសមស្របត្រូវមានផ្សំដោយអ្វីខ្លះ(ដូចជា តើការអភិវឌ្ឍដែលនាំមុខដោយវារីអគ្គិសនី គឺជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធិភាពសម្រាប់ជួយអ្នកក្រនៅក្នុងតំបន់ណាមួយជាក់លាក់ឬទេ?)។

អាស្រ័យហេតុនេះ ការមានឧបករណ៍សំរាប់វិភាគវាយតំលៃដែលអាចប្រើប្រាស់ សម្រាប់វាយតម្លៃ គុណភាពនៃផែនការយុទ្ធសាស្ត្រដាច់ដោយឡែក នៅមុនការវាយតម្លៃនៅកម្រិតគម្រោងមានសារៈប្រយោជន៍។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីដែលគម្រោងមួយបានផ្តើមដំណាក់កាលការរៀបចំ ហើយនោះ(ដូចជា ទំនប់ដុន សាហុង នៅក្នុងប្រទេសឡាវ) ដំណាក់កាលអនុវត្ត (ដូចជាទំនប់ណាមធឿង២ ក្នុងប្រទេសឡាវ ទំនប់ Ilisu នៅប្រទេសទួរគី) ឬដំណាក់កាលប្រតិបត្តិការ (ដូចជា ទំនប់ Gorges បី នៅប្រទេសចិន ប៉ាក់មុន នៅប្រទេសថៃ) តើចាំបាច់ត្រូវធ្វើការវាយតំលៃដូចក្នុង ផ្នែកទី១ ដែរឬទេ ? តើគួរផ្តល់អាទិភាពកម្រិតណាដល់ផ្នែកទី១ ធៀបនឹងផ្នែកដទៃទៀត?

នៅក្នុងករណីទំនប់ណាមធឿង២ អ្នករិះគន់ចង់ឱ្យមានការវាយតំលៃពេញលេញ។ពួកគេអះអាងថា មានការខ្វះខាតខ្លាំងក្នុងផែនការអភិវឌ្ឍន៍ថាមពលរបស់អតិថិជនថៃ (du Pont 2005; Greacen and Palettu 2007), និងការបង្ហាញហេតុផល ដែលជាឆ្អឹងខ្នងនៃ ផែនការអភិវឌ្ឍន៍ថ្នាក់ជាតិរបស់រដ្ឋាភិបាលឡាវ (Cavallo et al. 2008) ។ ផ្ទុយទៅវិញ អ្នកឧបត្ថម្ភគម្រោងអាចចង់ចាប់ផ្តើមការវិភាគវាយតំលៃដូចក្នុងផ្នែកទី២ ដែលទាក់ទងនឹងដំណាក់កាលអនុវត្ត ។ដូច្នេះ គេឃើញមានសក្តានុពល នៃ ការមិនចុះសម្រុងគ្នារវាងសម្ព័ន្ធភាពខុសៗគ្នានៃអ្នកដើរតួសំខាន់ៗអំពីវិសាលភាពនៃការវិភាគវាយតំលៃ។

នៅក្នុងបរិបទនៃគម្រោងអភិវឌ្ឍន៍ដែលល្អមួយ ការកសាងផែនការយុទ្ធសាស្ត្រ(ឧទាហរណ៍ ការវិភាគវាយតំលៃ អំពីជម្រើសអគ្គិសនី ផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងតំបន់) បានធ្វើឡើងតាមទម្រង់មួយដែលមានតម្លាភាព គ្មានលំអៀង និងតាមបែបផែននៃ ការចូលរួម។ការកសាងផែនការយុទ្ធសាស្ត្រ ត្រូវធ្វើឡើងយ៉ាងទៀងទាត់ និងមុនការសិក្សា នៅកម្រិតផ្សេងទៀតនៃគម្រោង។ រចនាសម្ព័ន្ធរបស់ HSAP ឆ្លុះបញ្ចាំងអំពីគោលគំនិតនៃការកសាងផែនការតាមវិធីនេះ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងនៅក្នុង អាងទន្លេមេគង្គ មានភាពខុសគ្នាឆ្ងាយណាស់ពីគោលគំនិតនេះ។ ជាក់ស្តែង អ្នកកសាងផែនការនៅក្នុងក្រុមហ៊ុនអគ្គិសនី មិនបានរួមបញ្ចូល គម្រោងអំពីប្រសិទ្ធិភាពថាមពល ជាបេក្ខភាពនៃជំរើស សម្រាប់ការវិនិយោគ នៅក្នុងផែនការអភិវឌ្ឍន៍ថាមពលសម្រាប់រយៈ ពេលយូរអង្វែងរបស់ខ្លួនឡើយ(du Pont 2005; Greacen and Palettu 2007)។នៅក្នុងប្រទេសអ្នកផ្គត់ផ្គង់ថាមពលវារីអគ្គិសនី គេមានការសិក្សាដើម្បីជម្រុះ

គម្រោងដែលគេមិនចង់បាន ប៉ុន្តែការសិក្សាទាំងនោះកម្រប្រើប្រាស់ជាការណែនាំសម្រាប់ចាត់ជាអាទិភាព នូវទីតាំងផលិតថាមពលវារីអគ្គិសនី តាមទម្រង់ ដែលមានតម្លាភាព និងតាមបែបផែននៃការចូលរួម ។ ជាជំនួស គម្រោងវារីអគ្គិសនីត្រូវបានបង្កើតឡើងតាមបែបសហគ្រាសនិងមិនមានការចូលរួមឡើយ ។នៅក្នុងបរិបទនេះ ឆន្ទៈដើម្បី ធ្វើការវិភាគវាយតំលៃដូចក្នុងផ្នែកទី១ តាមរូបភាពដែលមានតម្លាភាព ដោយគ្មានលំអៀង នឹងតាមបែបផែននៃការចូលរួម គឺជាការប្តេជ្ញាច្បាស់លាស់ជាងគេមួយសម្រាប់ការអភិវឌ្ឍដោយនិរន្តភាព ដែលក្រុមហ៊ុនថាមពលវារីអគ្គិសនីមួយ ឬ រដ្ឋាភិបាលជាម្ចាស់ផ្ទះ គួរធ្វើទៅបាន ។

## សារៈសំខាន់នៃការកសាងផែនការយុទ្ធសាស្ត្រ

តើការវិភាគវាយតំលៃអាចធ្វើឡើងបែបណា? តើការវាយតំលៃរបស់នរណា ដែរមានតំលៃ? ពិធីសារនេះ គួរតែផ្តល់ការណែនាំ គ្រប់គ្រាន់ ធ្វើយ៉ាងណានេះ ទោះអ្នកណាក៏ដោយធ្វើការវិភាគវាយតំលៃ ពួកគេអាចឈានដល់ការសន្និដ្ឋានប្រហែលគ្នា ។ សេចក្តីព្រាងនីតិវិធី នេះ នៅពុំទាន់ផ្តល់នៅឡើយទេ នូវការណែនាំគ្រប់គ្រាន់ ដូចដែលយើងពន្យល់ខាងក្រោមនេះ ។

ដោយហេតុថា ការវិភាគវាយតំលៃនិរន្តរភាពនៃវារីអគ្គិសនីត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យជាច្រើន ដូច្នេះវត្តមាននៃ ជំនាញលើមុខវិជ្ជាជាច្រើន គឺជាប្រការសំខាន់ ។ យោងតាម HSAP ក្រុមនៃអ្នកជំនាញការពហុឯកទេស អាចធ្វើការវិភាគវាយតំលៃ មួយដែលអាចទុកចិត្តបាន ។ ដើម្បីធ្វើបែបនេះបាន ពួកគេត្រូវការឱ្យមានវិធីសាស្ត្រមួយ ដើម្បីដាក់បញ្ចូលចំណេះដឹងរបស់ក្រុមប្រជាពលរដ្ឋទន់ខ្សោយ និងដែលងាយរងគ្រោះ ។ ការវិភាគវាយតំលៃក៏ត្រូវតែលៃលកផងដែរ ដើម្បីឱ្យសាធារណជន មានលទ្ធភាពទទួលបាននូវប្រភព ចំណេះដឹងសំខាន់ៗដទៃទៀត (ដូចជាការវិភាគជលសាស្ត្រ ម៉ូដែលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) សំរាប់យកមកពិនិត្យ ។

សេចក្តីព្រាងពិធីសារនេះ មិនបានពិភាក្សាអំពីអភិបាលកិច្ចនៃការវិភាគវាយតំលៃនោះជាលំអិតឡើយ ។ ការសង្ឃឹមថា អ្នកដើរតួដែល មានចំណាប់អារម្មណ៍ទាំងអស់ អាចសហការជាមួយគ្នា នៅក្នុងការរៀបចំឱ្យមានការវិភាគវាយតំលៃតែមួយរួមគ្នា គឺអាចមិនប្រាកដនិយម ឬគួរចង់បាននោះទេ ។ នៅក្នុងករណីណាក៏ដោយ គម្រោងខ្នាតធំដែលមានភាពចម្រូងចម្រាស់ គួរតែត្រូវដាក់ឱ្យមានការវិភាគវាយតំលៃយ៉ាងហ្មត់ចត់ និងដោយឯករាជ្យ ។

## ការវិភាគទម្រង់នៃសំណើពិធីសារ

### *សេចក្តីសង្ខេប*

ដូចមានបង្ហាញក្នុងតារាងទី១ ពិធីសារនេះ ទាមទារឱ្យមានការវិភាគវាយតំលៃផ្អែកលើលក្ខណៈវិនិច្ឆ័យ ("ទិដ្ឋភាព")ខុសៗគ្នាជាច្រើន ។HSAF បានស្នើឱ្យធ្វើការដោះស្រាយទិដ្ឋភាពលក្ខណៈវិនិច្ឆ័យនីមួយៗ ទៅតាមវិធីរួមមួយ :

(១) ទិដ្ឋភាពនីមួយៗ ផ្សំដោយសូចនាករចំនួនប្រាំពីរ សម្រាប់ការវិភាគវាយតំលៃជាលក្ខណៈស្តង់ដារៈ

- គុណភាពនៃដំណើរការវិភាគវាយតំលៃ
- គុណភាពនៃដំណើរការគ្រប់គ្រង
- គុណភាពនៃដំណើរការពិគ្រោះយោបល់
- កម្រិតនៃការគាំទ្ររបស់អ្នកពាក់ព័ន្ធនានា
- កម្រិតនៃការគោរពតាមការកំណត់
- កម្រិតនៃភាពស្របនឹងផែនការនានា
- កម្រិតនៃប្រសិទ្ធភាព

(HSAF 2009a: Section 1, p.6)

សេចក្តីព្រាងពិធីសារនេះ ហៅសូចនាករទាំងនេះថាជា "សញ្ញាសំគាល់" ។ ពិធីសារមានអត្ថបទពន្យល់វែង ឬ ខ្លី សំរាប់សញ្ញាសំគាល់នីមួយៗ ។

(២) ក្រោយពីប្រមូលទិន្នន័យបានគ្រប់គ្រាន់ហើយ ក្រុមអ្នកវាយតំលៃនឹងដាក់ពិន្ទុសម្រាប់សញ្ញាសំគាល់នីមួយៗខាងលើ (១="ខ្សោយ ខ្លាំង", ៥ = "ល្អបំផុត") ។

(៣) ពិធីសារ អាចចែកសញ្ញាសំគាល់នានាខាងលើ ទៅជាសំណួរតូចៗមួយចំនួនបន្ថែមទៀត ។ ឧទាហរណ៍ រូបទី ៣ បង្ហាញថា ការឆ្លើយ តបទៅនឹងគុណភាពនៃដំណើរការវិភាគវាយតំលៃ ទាមទារឱ្យឆ្លើយទៅនឹងសំណួរតូចៗចំនួនបួនថែមទៀត ។

### រូបទី១ ក្របខ័ណ្ឌរបស់ WCD សម្រាប់ការធ្វើសេចក្តីសម្រេច

| សញ្ញាសំគាល់ អំពីដំណើរការ | 5 | 4 | 3 | 2 | 1 |
|---|---|---|---|---|---|
| ការវិភាគវាយតំលៃ | • គុណភាពនៃដំណើរការដែលនាំទៅរកការយល់ដឹងអំពីតម្រូវការសេវាកម្មថាមពលនៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និងអន្តរជាតិ [1] | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| | • គុណភាពនៃដំណើរការដែលនាំទៅរកការយល់ដឹងអំពីតម្រូវការសេវាកម្មទឹកនៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និងអន្តរជាតិ [2] | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| | • គុណភាពនៃដំណើរការដែលនាំទៅរកការយល់ដឹងអំពីគោលបំណងអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន តំបន់ ជាតិ និងអន្តរជាតិ | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| | • (សំរាប់អ្នកអភិវឌ្ឍន៍គម្រោង) គុណភាពនិងដំណើរការដែលនាំទៅរកការយល់ដឹងអំពីយុទ្ធសាស្រ្តគម្រោង ដែលត្រូវគ្នាជាមួយតម្រូវការ និងគោលបំណងអភិវឌ្ឍន៍ | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| Management | ជាទូទៅ មិនពាក់ព័ន្ធទេ នៅក្នុងដំណាក់កាលនៃការវិភាគវាយតំលៃកំរិតជាយុទ្ធសាស្រ្ត | | | | |
| Consultation | • (សំរាប់រដ្ឋាភិបាល) គុណភាពនៃការពិគ្រោះយោបល់ដែលទាក់ទងទៅនឹងតម្រូវការដែលបង្ហាញឱ្យឃើញ (សូមអានការណែនាំអំពីការពិគ្រោះយោបល់) | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| Performance Attributes | 5 | 4 | 3 | 2 | 1 |
| Stakeholder Support | • (សំរាប់រដ្ឋាភិបាល) ការគាំទ្ររបស់អ្នកពាក់ព័ន្ធនានាដល់ការកំណត់អំពីតម្រូវការ និងគោលបំណងអភិវឌ្ឍន៍ (សូមអានការណែនាំអំពីការគាំទ្ររបស់អ្នកពាក់ព័ន្ធ) | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | ខ្សោយ | ខ្សោយណាស់ |
| Conformance with Plans | ជាទូទៅ មិនពាក់ព័ន្ធទេ នៅក្នុងដំណាក់កាលនៃការវិភាគវាយតំលៃកំរិតជាយុទ្ធសាស្រ្ត | | | | |
| Compliance | ជាទូទៅ មិនពាក់ព័ន្ធទេ នៅក្នុងដំណាក់កាលនៃការប៉ាន់ប្រមាណជាយុទ្ធសាស្រ្ត | | | | |
| Effectiveness | • (សំរាប់អ្នកអភិវឌ្ឍន៍) វិភាគទានដែលទំនងជាកើតចេញពីគម្រោង ដល់តម្រូវការ និងគោលបំណងអភិវឌ្ឍន៍ | | | | |
| | ខ្ពស់បំផុត | ខ្ពស់ | ល្អ | តិចតួច | គ្មាន |

**ប្រភព:** HSAF (2009a: Section 1, p. 23)

## *ការវិភាគ*

ពាក្យមិនច្បាស់លាស់–ដើម្បីឱ្យមានប្រយោជន៍ពិធីសារនេះត្រូវតែថែងបញ្ជាក់លក្ខណៈវិនិច្ឆ័យ(ទិដ្ឋភាព)និងសូចនាករ(សញ្ញាសំគាល់) ឱ្យបានច្បាស់លាស់ សមស្រប និងត្រឹមត្រូវ។ លក្ខណៈវិនិច្ឆ័យខ្លះនៅក្នុងពិធីសារនេះ ដូចជាការវាយតំលៃលើជម្រើសនានាត្រូវបានកំណត់លំអិតច្បាស់លាស់។លក្ខណៈវិនិច្ឆ័យជាច្រើនផ្សេងទៀត ត្រូវបានអធិប្បាយតាមលក្ខណៈច្របូកច្របល់។ឧទាហរណ៏នៅក្នុងលក្ខណៈវិនិច្ឆ័យស្តីពីតម្រូវការដែលអាចបញ្ជាក់ឱ្យឃើញច្បាស់ (រូបទី៣) សូចនាករ(សញ្ញាសំគាល់) ចំនួនពីរខាងក្រោមនេះ មានលក្ខណៈច្របូកច្របល់ :

(i) “គុណភាពនៃដំណើរការ ឱ្យវាយតំលៃឧ ដែលធ្វើឱ្យមានការយល់ដឹងអំពីគោលបំណងអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន តំបន់ជាតិ និងអន្តរជាតិ។”

(ii) (សំរាប់ក្រុមអ្នកអភិវឌ្ឍន៏) វិភាគទានដែលទំនងជាកើតចេញពីគម្រោង ដល់តម្រូវការ និងគោលបំណងអភិវឌ្ឍន៏”

(HSAF 2009a, p. 23)

សូចនាករ (i) ផ្សំដោយកម្រិតភូមិសាស្ត្រនៅបួនលំដាប់។ ការវាយតម្លៃលំដាប់ទាំងបួន អាចមានន័យថា ត្រូវប្រមូលភស្តុតាង និងការដាក់ពិន្ទុចំនួនបួនឈុត។ ប៉ុន្តែក្នុងតារាងមានតែកន្លែងមួយប៉ុណ្ណោះសម្រាប់ឆ្លើយនឹងសំណួរ។

សូចនាករ (ii) គឺស្តីពីប្រសិទ្ធិភាព។ សូចនាករនេះផ្តោតលើប្រសិទ្ធិភាពនៃសំណើគម្រោងមួយ។ សំណួរ នេះពិតជាមានការពាក់ព័ន្ធសម្រាប់ការពិចារណាដោយគ្រប់អ្នកពាក់ព័ន្ធទាំងអស់មិនមែនត្រឹមតែសំរាប់ក្រុមអ្នកអភិវឌ្ឍន៏នោះឡើយ។

ប្រការសំខាន់ជាងនេះទៀតគឺ បើផ្អែកតាមទស្សនៈវិស័យនិរន្តរភាព យើងត្រូវធ្វើការវាយតំលៃមិនត្រឹមតែប្រសិទ្ធិភាពនៃសំណើគម្រោងនោះទេ។ យើងក៏ត្រូវតែវាយតំលៃអំពីថាតើ "តម្រូវការ និងគោលបំណងអភិវឌ្ឍន៏ជាក់លាក់នានា" អាចនឹងឈានដល់ការអភិវឌ្ឍដោយចិរភាពតាមរបៀបណា។សំណួរដែលកាន់តែមានសារៈសំខាន់អំពីប្រសិទ្ធិភាព ពុំមាននៅក្នុងលក្ខណៈវិនិច្ឆ័យ ស្តីពីតម្រូវការដែលត្រូវបង្ហាញឱ្យឃើញច្បាស់លាស់នោះទេ (សូមអានផ្នែកទី៦ ខាងក្រោម) ។ ចូរប្រៀបធៀបចំណុចនេះជាមួយនឹង លក្ខណៈវិនិច្ឆ័យអំពីការវាយតំលៃលើជម្រើស (ទិដ្ឋភាព I-2) ដែលសូចនាករអំពីប្រសិទ្ធិភាព មានខ្លឹមសារខ្លាំងជាង :

“កម្រិតនៃការប៉ាន់ប្រមាណជម្រើសនានា ដែលអាចផ្តល់ជាមូលដ្ឋានដើម្បីសម្រេចយកជម្រើសបែបណាមួយនៃការអភិវឌ្ឍដោយផ្អែកលើលក្ខណៈវិនិច្ឆ័យអំពីនិរន្តរភាព។” (HSAF 2009a, p. 24)

នៅក្នុងផ្នែកទី៥ យើងពិភាក្សាអំពីសារៈសំខាន់នៃការភ្ជាប់ទំនាក់ទំនងរវាង HSAP ទៅ"លក្ខណៈវិនិច្ឆ័យនិរន្តរភាព"។

វិធីនៃការបកស្រាយ - ការវិភាគវាយតំលៃទូទៅនិងវិធីដាក់ពិន្ទុ មានទំនោរជាខ្លាំងទៅលើការបកស្រាយ។ទស្សនៈវិជ្ជានៃការបកស្រាយ អះអាងថា ពុំមានតថភាពសោះឡើយ។ គុណភាពនៃផែនការអភិវឌ្ឍន៏ថាមពល ឬ ទំនប់វារីអគ្គិសនីណាមួយ អាស្រ័យទៅលើថាតើ អ្នកដើរតួសំខាន់ៗ បកស្រាយផែនការ ឬ ទំនប់នោះបែបណា។ ទស្សនៈវិជ្ជានៃវិទ្យាសាស្ត្រ បដិសេធការអះអាងថាមានតែ ចំណេះដឹង"ពិតប្រាកដ"តែមួយប៉ុណ្ណោះ (Sayer 2000; Blaauw and Pritchard 2005) ។

ដោយសារ HSAP គឺជាការប៉ុនប៉ង ដើម្បីបង្កើតនូវទំរង់នៃចំណេះដឹងគ្មានលំអៀងនិងអាចគណនាជាចំនួនទៅបាន យើងមានការភ្ញាក់ផ្អើល ដោយឃើញថា HSAP វាពឹងផ្អែកលើវិធីមួយដែលមាននិន្នាការជាការបកស្រាយខ្លាំងពេក។

នៅក្នុង HSAP ការដាក់ពិន្ទុជាលេខ ច្រើនតែផ្អែកលើពាក្យដូចជា"គ្រប់គ្រាន់"និង"ប្រសិទ្ធិភាព"។ពាក្យគន្លឹះនីមួយៗទាំងនេះត្រូវបានប្រើប្រាស់ជាច្រើនដង។ ពាក្យទាំងនេះបានកំណត់និយមន័យក្នុងកំរិតមួយដែលទាមទារអោយមានការបកស្រាយថែមទៀត។ យោងតាម HSAF:

*“ប្រសិទ្ធិភាព” មានន័យថា “បង្កើត ឬ លទ្ធភាពបង្កើតនូវឥទ្ធិពលទៅតាមបំណង តាមការរំពឹងទុក និង/ឬដែលចង់បាន” “គ្រប់គ្រាន់” មានន័យថា “សមល្មម ឬ សមគួរ ដើម្បីបំពេញលក្ខខណ្ឌ ឬ ការចាំបាច់មួយ ”*

*(HSAF 2009: ផ្នែកទី ១, ទំព័រ ១៧ គូសបញ្ជាក់ជាបន្ថែម)*

តើអ្នកណាទៅជាអ្នកសម្រេចថាតើឥទ្ធិពល(ពោលគឺ លទ្ធផល) អ្វីខ្លះ ដែលគេចង់បាន? តើអ្នកណាកំណត់អំពីថាតើលក្ខខណ្ឌ និងតម្រូវការបែបណា ដែលស្របច្បាប់? ពួកអភិរក្សនិយមអាចអះ

អាងថា "លក្ខខណ្ឌ" គ្មានអ្វីហួសក្រៅពីច្បាប់ និងនីតិវិធីដែលមានស្រាប់របស់ជាតិនោះឡើយ ហើយលទ្ធផលដែលជាការចង់បានមានចែងនៅក្នុងផែនការអភិវឌ្ឍន៍នានារួចស្រាប់។ ដូចដែល Gibson (2006) បានពោលគួរអោយចងចាំថា គេចាំបាច់ត្រូវមាននូវកំរងនៃលក្ខណ៍ និងលទ្ធផលកាន់តែស៊ីជំរៅជាងនេះ ប្រសិនបើគេចង់ឱ្យសង្គមមនុស្សជាតិអាចផ្តល់បានជីវភាព រស់នៅសមរម្យសំរាប់ជនគ្រប់គ្នាដោយមិនឱ្យខូចខាតដល់ពិភពផែនដីនោះ។

យោងតាមសេចក្តីព្រាងពិធីសារនេះ ពិន្ទុ ៥ នឹងត្រូវផ្តល់អ្វីដែលអាចអះអាងជា "ទម្លាប់ល្អ"។ ទោះជាយ៉ាងណាក៏ដោយអនុលោមតាមវិធីនៃការបកស្រាយ សេចក្តីព្រាងពិធីសារនេះអនុញ្ញាតឱ្យមានភាពខុសៗគ្នានៃអ្វីដែលហៅថា "ទម្លាប់អនុវត្តល្អៗ ដែលមានភស្តុតាងបញ្ជាក់" សំរាប់ប្រទេស និងគម្រោងដែលមានទំហំខុសៗគ្នា។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការពិគ្រោះយោបល់ជំហានទី២ តាមអ៊ិនធឺណិតដែលវេទិកានេះ បានសុំឱ្យសាធារណជនលើកស្នើឧទាហរណ៍នៃអំពី "ទម្លាប់អនុវត្តល្អៗដែលមានភស្តុតាងបញ្ជាក់" សម្រាប់សូចនាករនីមួយៗ នៅក្នុងនីតិវិធីនេះ (HSAF 2009a: 1)។

HSAP គួរតែបានដាក់បញ្ចូលស្តង់ដារដាច់ខាតកាន់តែច្រើនជាងនេះ។ សូចនាករ (សញ្ញាសំគាល់) នីមួយៗ គួរតែអាចផ្តល់ឱ្យអ្នកប្រើប្រាស់ នូវឧទាហរណ៍ច្បាស់លាស់អំពីទម្លាប់អនុវត្តជឿនលឿនសម្រាប់ជាមូលដ្ឋានដើម្បីដាក់ពិន្ទុលើការអនុវត្តដែលគេពិនិត្យ។

ឧទាហរណ៍ច្បាស់លាស់អំពីការអនុវត្តដែលកើនឡើងជាលំដាប់ ដែលបានប្រើប្រាស់ ឬ ទទួលយកដោយឧស្សាហកម្មពាក់ព័ន្ធនឹងថាមពល រួមមាន :

- ការកសាងផែនការសមាហរណកម្មអគ្គិសនី ឬ សេវាកម្មទឹក (ដែលគេស្គាល់ផងដែរថាជាការកសាងផែនការធនធាន បែបសមាហរណកម្ម) ដែលជាលក្ខខណ្ឌ នៃបទប្បញ្ញត្តិ សម្រាប់អង្គការថាមពលជាច្រើននៅអាមេរិកខាងជើង (D'Sa 2005)
- ការទទួលបាន នូវការឯកភាពជាមុន ដោយសេរី និងមានការយល់ដឹង ពីសំណាក់តំណាងនៃអ្នករងគ្រោះពីគម្រោង ដែល បានអនុម័តនៅក្នុងកិច្ចប្រជុំតុមូល ស្តីពីការផលិតប្រេងដូងដោយនិរន្តរភាព (RSPO 2007)។

ការធ្វើអត្តសញ្ញាណអ្នកពាក់ព័ន្ធ - ដូចបានពិភាក្សាខាងដើម សេចក្តីព្រាងHSAP បន្សល់ទុកការកំណត់អំពីវិសាលភាពនៃតម្រូវការស្របច្បាប់ (និងនិយមន័យជាក់លាក់ទៅតាមករណីនីមួយៗ អំពីភាពគ្រប់គ្រាន់ ភាពសមស្រប និងប្រសិទ្ធិភាព) ទៅតាមការយល់ឃើញរបស់ក្រុមអ្នកពាក់ព័ន្ធនានា។ ក្នុងករណីប្រសើរបំផុត វិធីធៀបបែបនេះ អាចនឹងនាំទៅរកការពិភាក្សាដោយចំហ រវាងសវនករ និងអ្នកពាក់ព័ន្ធដទៃទៀត អំពីថាតើត្រូវបំពេញឱ្យបានតាមលក្ខខណ្ឌ និងតម្រូវការសំខាន់ៗអ្វីខ្លះ (ពោលគឺ គុណតម្លៃខាងសង្គម អាទិភាព គោល នយោបាយ)។ ប៉ុន្តែកម្រិតនៃការពិភាក្សា និងការវាយតំលៃ ដែលពិតជាមានន័យ អាចនឹងកើតមានទៅបាន អាស្រ័យលើរបៀប នៃការធ្វើអត្តសញ្ញាណនិងជ្រើសរើសអ្នកពាក់ព័ន្ធបែបណាឱ្យចូលរួម។

HSAP ទទួលស្គាល់អ្នកពាក់ព័ន្ធចំនួនប្រាំក្រុម (សូមអានរូបទី៤)។ កម្រិតដែលអ្នកពាក់ព័ន្ធផ្សេងៗគ្នាគាំទ្រ ដល់ដំណើរការវាយតំលៃការគ្រប់គ្រង និងការពិគ្រោះយោបល់ និងលទ្ធផល គឺជាសូចនាករដ៏សំខាន់នៃនិរន្តរភាព។ វាជាសូចនាករស្តង់ដារ (សញ្ញាសំគាល់) និងមាននៅទូទាំងពិធីសារនេះ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសេចក្តីព្រាងពិធីសារនេះ សូចនាករស្តីពី "ការគាំទ្រពីអ្នកពាក់ព័ន្ធ" មានការពាក់ព័ន្ធជាពិសេសទៅនឹងក្រុមអ្នកពាក់ព័ន្ធដែល "រងគ្រោះដោយផ្ទាល់"។ ការយកចិត្តទុកដាក់ បានផ្តោតលើកម្រិតគាំទ្រពីក្រុម "ដែលរងគ្រោះដោយផ្ទាល់" ចំពោះដំណើរការ ឬ លទ្ធផលណាមួយ។

គេមានការលំបាកជាច្រើនក្នុងការអះអាងថា សំណើនិយមន័យអំពីអ្នកពាក់ព័ន្ធដែល "រងគ្រោះដោយផ្ទាល់" គឺជាក្រុមអ្នកដែលមាន "សិទ្ធិហានិភ័យ និងការទទួលខុសត្រូវខ្លាំង ចំពោះបញ្ហាក្នុងគម្រោងមួយ" (រូបទី៤)។ ជាបឋម វាមិនច្បាស់លាស់។ តើអ្នកណាជាអ្នកកំណត់កំរិត "ខ្លាំង"?

ទីពីរ គេក៏ត្រូវបំភ្លឺផងដែរអំពីន័យដែលថា អ្នកដើរតួនានារងគ្រោះដោយផ្ទាល់ "ពីសំណាក់នៃបញ្ហារបស់គម្រោងមួយ"។ អ្នកដើរតួមានច្រើន មានផលប្រយោជន៍វិជ្ជាជីវៈរបស់ខ្លួន ក្នុងថាមពល ទឹក និងការអភិវឌ្ឍដោយចីរភាព ដូចជាអ្នកវិទ្យាសាស្ត្រ អ្នកកសាងផែនការ មេដឹកនាំយោបល់សាធារណជន

បុគ្គលធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ និងតំណាង នៃ សហគមន៍ជនរងគ្រោះ ដោយសារគម្រោង។ គេគួរកត់សំគាល់ដែរថា ក្រុមអ្នកដើរតួនៅក្នុងជំពូកទីពីរនេះ រួមមានទាំង អង្គការនៅក្នុងស្ថាប័នរដ្ឋ និងក្រៅស្ថាប័នរដ្ឋផងដែរ។ តើអង្គការនីមួយៗក្នុងចំណោមក្រុមទីពីរនេះ ចាំបាច់ត្រូវតែបង្ហាញហេតុផលពីការអះអាងរបស់ខ្លួនទៅតាមករណីនីមួយៗ ដាច់ដោយឡែកពីគ្នាដែរឬទេ ដើម្បីត្រូវបានចាត់ទុកជាអ្នកពាក់ព័ន្ធ"ដែលរងគ្រោះដោយផ្ទាល់"?

**រូបទី ៤. និយមន័យអំពីប្រភេទអ្នកពាក់ព័ន្ធ**




**ប្រភព:** HSAF 2009a: Section 1, p. 19

នៅខាងក្រៅតំបន់រងគ្រោះដោយសារគម្រោងHSAP បានកត់សំគាល់ស្ថាប័នហិរញ្ញវត្ថុ ក្រុមអ្នកអភិវឌ្ឍន៍គម្រោង និងស្ថាប័ន និយ័តកម្ម ជាអ្នកដើរតួ ដែលអាចចាត់ទុកថា"រងគ្រោះដោយផ្ទាល់"ដោយមានលក្ខណ៍ (HSAF 2009a: Section 1, p. 18). ការធ្វើបែបនេះ ប្រហែលជាបានផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវខុសៗគ្នារបស់ពួកគេ តាមផ្លូវច្បាប់ វិជ្ជាជីវៈ និងសីលធម៌។ គេពុំមានការ ណែនាំជាក់លាក់ អំពីរបៀបធ្វើការវាយតំលៃអំពីសិទ្ធិទទួលស្គាល់របស់ពួកគេនោះឡើយ។

ជារួមសេចក្តីព្រាង HSAP មិនទាមទារឱ្យមានការវាយតំលៃអំពីកម្រិតនៃការគាំទ្ររបស់ "អ្នកពាក់ព័ន្ធ"នៅក្នុងសង្គមទេ។ សំណើឱ្យមានការកំណត់ភាពខុសគ្នានៃអ្នកពាក់ព័ន្ធទាំងនេះ អាចឱ្យអ្នកអាន យល់ថាពួកគេ ជាពពួកផ្លូវរដ្ឋនិង មិនតំណាង ឱ្យសង្គមទាំងមូលឡើយ។

សង្គតិភាពនៃការកំណត់ស្តង់ដាររវាងលក្ខណៈវិនិច្ឆ័យនានា–សំរាប់លក្ខណៈវិនិច្ឆ័យខ្លះៗ សេចក្តីព្រាង HSAP ចែងណែនាំ ជាក់លាក់ ឬ ស៊ីជំរៅអំពីអ្វីដែលចាំបាច់ត្រូវតែបំពេញឱ្យបានតាមស្តង់ដារ ។នៅក្នុងករណីផ្សេងទៀត មានការចែងតិចតួចជាង :

- សំរាប់លក្ខណៈវិនិច្ឆ័យដែលទាក់ទងនឹងប្រជាពលរដ្ឋជាជនជាតិដើម និងការតាំងទីលំនៅឡើងវិញ (សូមអាន ទិដ្ឋភាព II-15

និង II-16), ដើម្បីទទួលបានពិន្ទុខ្ពស់បំផុត គេចាំបាច់ត្រូវតែមានការឯកភាពមតិពេញលេញពីក្រុមអ្នកពាក់ព័ន្ធនានា តាមរយៈ កិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់។ នេះជាឧទាហរណ៍មួយអំពីការណែនាំច្បាស់លាស់និងយ៉ាងច្រើន។

- សំរាប់លក្ខណៈវិនិច្ឆ័យដែលទាក់ទងនឹងការវាយតំលៃអំពីជម្រើស (ទិដ្ឋភាព I-2), គេមិនបានតំរូវឱ្យមានការ វិភាគវាយតំលៃគ្រប់ជ្រុងជ្រោយលើការកាត់បន្ថយ លើសេចក្តីត្រូវការ និងការផ្គត់ផ្គង់ (ធនធានថាមពល,ទឹក) ដើម្បីសំរេចតំលៃចំណាយទាបបំផុត ដើម្បីទទួលពិន្ទុកខ្ពស់បំផុតឡើយ។

លក្ខណៈវិនិច្ឆ័យខ្លះ ភ្ជាប់ជាមួយនូវសេចក្តីពន្យល់យ៉ាងលំអិត (សូមអាន លំហូរបរិស្ថាន និងនិរន្តរភាពនៅតំបន់ខ្សែទឹកខាង ក្រោម ទិដ្ឋភាព II-25)។ ក៏ប៉ុន្តែ សម្រាប់លក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលសំខាន់ដូចគ្នា គេឃើញមានការចែងលំអិត ក្នុងកម្រិតតិចជាងយ៉ាងច្រើន (សូមអាន ការវិភាគវាយតំលៃជម្រើសនានា)។ សេចក្តីព្រាង HSAF នៅពុំទាន់បានចែងអំពីស្តង់ដារដាច់ ខាតច្បាស់លាស់ អំពីការអនុវត្ត ជឿនលឿន សំរាប់លក្ខណៈវិនិច្ឆ័យទាំងអស់នៅឡើយទេ។

ការធ្វើអត្តសញ្ញាណនិងការប្រមូលទិន្នន័យ – HSAF ស្នើថា ការសាកល្បងអនុវត្តសេចក្តីព្រាងពិធីសារនេះអាចធ្វើឡើងដោយក្រុមសវនករមួយដែលមានសមាសភាពពីបី ទៅប្រាំមួយនាក់នៅក្នុងរយៈពេលបីថ្ងៃ (រួមទាំងទស្សនៈកិច្ចនៅតាមទីតាំងជាក់ស្តែង)។ការសាកល្បងអាចចាត់ចែងដោយក្រុមហ៊ុនវារីអគ្គិសនីមួយនិងគាំទ្រដោយអ្នកបកប្រែមួយរូប។ក្រុមហ៊ុននោះអាចសម្រួលឱ្យក្រុមអ្នកវាយតំលៃ បានចូលជួបអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលរួមទាំង តំណាងក្រុមហ៊ុន និងតំណាងរដ្ឋាភិបាល តំណាងសហគមន៍ និងអ្នកជំនាញការក្នុងស្រុកផងដែរ។

ទិន្នន័យ ដែលសេចក្តីព្រាងពិធីសារនេះ បានចាត់ទុកថាជាប្រភពនៃ"ភស្តុតាង" នៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ ឧទាហរណ៍ សេចក្តីព្រាង HSAF លើកស្នើថា ការគាំទ្ររបស់សហគមន៍នានាដែលរងគ្រោះដោយសារគម្រោង ត្រូវតែអាចវាយតំលៃបាន តាមរយៈការពិនិត្យមើលការអង្កេតនានានិងការធ្វើប្រជាមតិដែលធ្វើឡើងនៅកម្រិតសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ ជាញឹកញាប់ នយោបាយអំពីការអភិវឌ្ឍវារីអគ្គិសនី រាប់បញ្ចូល ការបញ្ចុះបញ្ចូលយ៉ាងខ្លាំងក្លានៅថ្នាក់មូលដ្ឋាន ពីសំណាក់អាជ្ញាធរនានា ដែលជាអ្នកគាំទ្រឱ្យមានសំណើគម្រោង។ ការធ្វើប្រជាមតិ និងការអង្កេតនានា អាចផ្តល់លទ្ធផលដែលមិនសុក្រឹត្យ និងត្រូវតែបំពេញបន្ថែមតាមរយៈបច្ចេកទេសដែលកាន់តែមានការឆ្លើយតបបានប្រសើរជាងមុន ដូចជា ការផ្សព្វផ្សាយដល់ក្រុមអ្នកងាយរងគ្រោះ និង ដែលពាក់ព័ន្ធ បន្ទាប់មកមានការសម្ភាសដោយមិនបើកចំហ។ ការចុះប្រមូលទិន្នន័យតែក្នុងរយៈពេលខ្លី ដែលចាត់ចែងដោយតំណាងពីក្រុមហ៊ុនវារីអគ្គិសនី អាចមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។

លក្ខខណ្ឌទន់ខ្សោយសម្រាប់ការចងក្រងជាឯកសារអំពីដំណើរការ និងលទ្ធផល? – ដើម្បីអាចធ្វើការវិភាគវាយតំលៃបានចប់សព្វគ្រប់សវនករនានាត្រូវតែបង្ហាញពីការយល់ដឹងលំអិតលើដំណើរការកសាងផែនការ និងអំពីស្ថាប័ននានានៅក្នុងប្រទេស ឬ តំបន់ ណាមួយជាក់លាក់។

ឧទាហរណ៍ ការយល់ដឹងលំអិតនោះ គឺជាប្រការចាំបាច់ ដោយសារពង្រាងពិធីសារនេះទាមទារឱ្យសវនករ បញ្ជាក់ ថាតើ គេអាច"គ្រប់គ្រង" ការប្រឈមខាង"ស្ថាប័ន"នានាបានក្នុងកម្រិតណា។ ឧទាហរណ៍មានរាប់បញ្ចូល "គម្លាត" ឬ "ការខ្វះខាត"នានា ដែលទាក់ទងនឹងគោលនយោបាយជាតិ ផែនការ និងសមត្ថភាពវិស័យសាធារណៈ (HSAF 2009a: Section 1: pp. 26, 29)។

ជាជំហានទាំមុខមួយសមស្រប ការវាយតំលៃបែបនេះ ទាមទារឱ្យបង្ហាញថា សវនករយល់ដឹងអំពីអ្វីដែលជា គម្លាត ដែលមាននៅក្នុងដំណើរការកសាងផែនការ ឬ បរិបទខាងស្ថាប័នជាក់លាក់មួយ។ ប៉ុន្តែ វាជាការចម្លែកណាស់ដែរ ដែលពង្រាងពិធីសារនេះ មិនតម្រូវឱ្យសវនករធ្វើសេចក្តីរាយការណ៍អំពីការយល់ដឹងរបស់ខ្លួនជាលំអិត។

វាជាការសមស្របសម្រាប់៖ SAF ក្នុងការចាត់ជាអាទិភាពនៃការគ្រប់គ្រងនូវបញ្ហា- ប៉ុន្តែការធ្វើបែបនេះ តាមរបៀបរំលងចោលការចងក្រងជាឯកសារដោយសត្យានុម័តអំពីស្ថានភាពនានា គឺពិតជាមិនអាចផ្តល់ផលបានល្អឡើយ។ វាអាច ធ្វើឱ្យអ្នកពាក់ព័ន្ធខ្លះយល់ថា ជាការបិទបាំង ឬ ការធ្វើការមិនបានស៊ីជម្រៅ។ យើងស្នើថា សវនករត្រូវតែដាក់ភ្ជាប់ជាមួយនូវឯកសារចងក្រងលំអិត (ករណីសិក្សា) ជាងនេះទៅទៀត។

ភាពស្មុគស្មាញនិងការនៅដាច់ដោយឡែកពីគ្នា – កម្រាស់ និងភាពស្មុគស្មាញនៃសេចក្តីព្រាងពិធីសារ (ទិដ្ឋភាពចំនួន៣៩ និង សូចនាករចំនួនជាង២០០ ដែលតម្រូវឱ្យដាក់ពិន្ទុ) អាចរឹតត្បិតការចូលរួមជាសាធារណៈប្រកបដោយការយល់ដឹងបានពេញលេញ។ ក្រៅពីនេះ ក៏មានហានិភ័យមួយដែរ នៅពេលឆ្លើយនឹងសំណួរតាមសូចនាកររាប់សិប លក្ខណៈវិនិច្ឆ័យនិរន្តរភាពសំខាន់ខ្លះៗ អាចត្រូវបំភ្លេចចោល។ ឧទាហរណ៍ សេចក្តីព្រាង HSAF បង្ហាញពីលក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់អាទិភាព ជម្រើសថាមពលនិងសេវាកម្មទឹកនៅចុងក្រោយគេបំផុតនៃសេចក្តីពន្យល់ការណែនាំដល់ការវាយតំលៃអំពីជម្រើស (HSAF 2009a, Section 1, p. 25)។

# ផែនកំណត់ និងសក្តានុពលនៃសេចក្តីព្រាង HSAP

សេចក្តីព្រាងHSAP គឺជាវិធីវាយតម្លៃមួយដែលផ្អែកលើពហុលក្ខណៈវិនិច្ឆ័យ ដែល នៅក្នុងនោះលក្ខណៈវិនិច្ឆ័យ វាស់អំពីគុណភាព (ទិដ្ឋភាព) ជាច្រើនត្រូវបានពិន្ទុកស្មើគ្នា។ ក្នុងន័យនេះ សេចក្តីព្រាពិធីសារនេះមានសក្តានុពលដើម្បី ប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចខាងគោលនយោបាយសាធារណៈ ប៉ុន្តែមិនអាចជំនួសការសម្រេចទាំងនោះបានឡើយ។

នៅក្នុងតំបន់មេគង្គ អ្នករិះគន់លើទំនប់វារីអគ្គិសនីខ្នាតធំ បានអះអាងថា ការផ្តល់សេវាកម្មអគ្គិសនីអាចធ្វើបានតាមរយៈ ជម្រើសផ្នែកបច្ចេកទេសខុសៗគ្នាចំណែកការចិញ្ចឹមជីវិតរបស់កសិករតូចតាចដែលពឹងផ្អែកលើតំបន់ដីសើម និងទន្លេ មិនអាច រកអ្វីមកផ្លាស់ប្តូរ ឬ ជំនួសបានឡើយ (Foran and Manorom 2009; Ubon Ratchatani University [UBU] 2002)។អំណះអំណាងនេះពាក់ព័ន្ធនឹងការចង់ឱ្យមានលក្ខណៈវិនិច្ឆ័យមួយឈុត (ការទ្រទ្រង់និរន្តរភាពនៃធនធានទឹកដែលជាសម្បត្តិរួម សម្រាប់ការចិញ្ចឹមជីវិតរបស់ប្រជាជន) ឱ្យនៅខ្ពស់ជាងលក្ខណៈវិនិច្ឆ័យមួយផ្សេងទៀត (វារីអគ្គិសនី)។ តាមការយល់ឃើញរបស់យើង សេចក្តីព្រាង HSAF ពុំមានគោលដៅលំអៀងទៅខាងណាឡើយ ក្នុងរបៀបឱ្យតម្លៃលើផលិតផលនានា។

នៅទីបំផុត ការសម្រេចនានាថា តើទំនប់ណាមួយ គួរតែសាងសង់ឡើង ដាក់ឱ្យប្រតិបត្តិការ ឬ ចាប់ផ្តើមអនុវត្តដែរឬទេ គឺជាការសម្រេចដែលធ្វើឡើងដោយអ្នកដើរតួច្រើនគ្នាដែលមានចំណាប់អារម្មណ៍លើគុណតម្លៃ និងអំណះអំណាងខុសៗគ្នា។ អាស្រ័យហេតុនេះ យើងក៏មើលឃើញអំពីភាពចាំបាច់ឱ្យមានការណែនាំសំខាន់ៗជាបន្ថែមសម្រាប់អ្នកពាក់ព័ន្ធនានា គិតអំពីនិរន្តរភាពផងដែរ។

ចំណុចសំខាន់ៗអំពីនិរន្តរភាព - ដើម្បីជួយអ្នកពាក់ព័ន្ធនានាក្នុងការវាយតម្លៃអំពីនិរន្តរភាព ជាការល្អគេត្រូវពិនិត្យមើល ចំណុចគន្លឹះនានានៅក្នុង“វិធានជាក់ស្តែង” របស់ Robert Gibson (2006) សម្រាប់ការវិភាគវាយតំលៃអំពីនិរន្តរភាព។ លោក Gibson ដែលជាអ្នកជំនាញការវាយតម្លៃបរិស្ថាន មានបទពិសោធន៍ក្នុងវិស័យអាជីវកម្មរ៉ែ បានអះអាងថា ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ លើកិច្ចការពារដល់ការចិញ្ចឹមជីវិត សហគមន៍ដែលមានសុខភាពល្អនិងរស់រវើក ឱកាសនិងជម្រើសថ្មីៗ និងឥទ្ធិពលលើការសម្រេចនានា (2006: 173). ការវាយតម្លៃអំពីនិរន្តរភាព គួរតែជាឱកាសមួយ ដើម្បីសិក្សា និងគិតគូរអំពីចំណងទាក់ទង នៅក្នុងប្រព័ន្ធសង្គម-អេកូឡូស៊ីផងដែរ។លោកបានអះអាងថា:

> ការវាយតម្លៃនិរន្តរភាព ត្រូវតែគិតគូរដោយហ្មត់ចត់អំពីកាតព្វកិច្ច ដើម្បីទទួលស្គាល់អំពីការពឹងផ្អែកលើគ្នាទៅវិញទៅមក និងការស្វែងរកផលចំណេញជាច្រើនដែលពង្រឹងគ្នាទៅវិញទៅមកនៅក្នុងគ្រប់ផ្នែក។ ប្រការនេះអាចកែលម្អបាន តាមរយៈការបង្កើតរបៀបវារៈទូលំទូលាយមួយដែលគ្របដណ្តប់លក្ខខណ្ឌស្នូលទាំងអស់ សម្រាប់ឈានទៅនិរន្តរភាព។ ប៉ុន្តែប្រការសំខាន់គឺត្រូវ តែបង្កើតការណែនាំជាក់លាក់សម្រាប់ការសម្រេច ដែលផ្តល់សម្បទានឱ្យគ្នាទៅវិញទៅមកផងដែរ ដើម្បីធានាថា ការធ្វើពលិកម្ម អាចនឹងកើតមាន តែក្នុងករណីដែលពុំមានជម្រើសជំនួសសមស្របដែល"មិនសូវអាក្រក់" ជាងនេះ។(Gibson 2006: 172; មានការគូសបញ្ជាក់បន្ថែម)

នៅក្នុងវាក្យខ័ណ្ឌនេះ គេមានអំណះអំណាងចំនួនបីដែលទាក់ទងគ្នាដែលសុទ្ធតែសង្កត់ធ្ងន់លើសារៈសំខាន់នៃចំណងទាក់ទងគ្នា។ សញ្ញាណអំពី"ផលចំណេញដែលពង្រឹងគ្នាទៅវិញទៅមក" ស្នើឱ្យមានការជ្រើសរើសដោយម៉ត់ចត់នូវផែនការ ឬ ទំនប់ដែលល្អបំផុត (ក៏ ដូចជាការស្រាវជ្រាវជាបន្តរផងដែរ) និងមិនមែនជាលំហាត់មួយដើម្បីរើសយកផែនការ ឬទំនប់ដែលល្អជាងពីក្នុងចំណោម ជម្រើសដែលអាក្រក់នោះឡើយ។

ទីពីរ លោក Gibson អះអាងថា គេអាចកំណត់សំគាល់ លក្ខខណ្ឌស្នូលអំពីនិរន្តរភាព ដែលជាប្រការសំខាន់ៗ និងដែលជា ទូទៅអាចទទួលយកបាន។លក្ខខណ្ឌទាំងនោះអាចនឹងចែងតាមវិធីខុសៗគ្នា ប៉ុន្តែលក្ខខណ្ឌ

ទាំងអស់សុទ្ធតែពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យ សំខាន់ៗ ដូចជា :

- កាត់បន្ថយការគំរាមកំហែងដោយផ្ទាល់និងប្រយោលពីមនុស្សមកលើសុចរិតភាពនៃប្រព័ន្ធ
- ផ្តល់ឱកាសសមរម្យសម្រាប់ការចិញ្ចឹមជីវិត
- សមធមិវវាំងមនុស្សនៅក្នុងជំនាន់តែមួយ
- សមធមិរវាំងមនុស្សក្នុងជំនាន់ខុសៗគ្នា
- ការថែរក្សាធនធាន និងភាពផ្តល់ផល
- ការគោរពចំពោះសង្គម-អេកូឡូស៊ីនិងអភិបាលកិច្ចប្រជាធិបតេយ្យ

(Gibson 2006: 174)

ឧទាហរណ៍ ភាពផ្តល់ផល និងសមធមិមានន័យថា បង្កើតវិធានដែលត្រូវការចំណាយសម្ភារៈនិងថាមពលតិចជាង ដើម្បីបំពេញតម្រូវការរបស់បុគ្គលក្នុងក្រុមអ្នកមាន ដើម្បីអនុញ្ញាតឱ្យមានការផ្តល់សម្ភារៈនិងថាមពលបានគ្រប់គ្រាន់ សម្រាប់មនុស្សគ្រប់រូប។ ដើម្បីឱ្យមានការគោរព គេទាមទារឱ្យមានការកសាងសមត្ថភាព និងជម្រុញអ្នកផលិត និងអ្នកប្រើប្រាស់ទាំងអស់ឱ្យកាត់បន្ថយស្លាកស្នាមគ្រោះថ្នាក់ចំពោះសង្គម-អេកូឡូស៊ី ដោយមិនត្រឹមតែនៅក្នុងវិស័យវារីអគ្គិសនីនោះឡើយ (2006:174)។

ពិធីសារលំអិតមួយដូចជា HSAF គួរតែផ្សារភ្ជាប់ឱ្យបានច្បាស់លាស់ទៅនឹងលក្ខខណ្ឌស្នូលនៃនិរន្តរភាព។ ការធ្វើបែបនេះ អាចផ្តល់ឱ្យអ្នកពាក់ព័ន្ធនានា ឱ្យមានទំនុកចិត្តលើ HSAF ជាមូលដ្ឋានដែលបានរៀបចំឡើងលើគ្រឹះនៃចំណេះដឹងមោះមុត។ ដើម្បីឱ្យច្បាស់លាស់ លក្ខខណ្ឌស្នូលនៃនិរន្តរភាពដែលបានពិភាក្សាខាងលើ បានលើកពីបញ្ហា ដែលហួសពី ការអភិវឌ្ឍថាមពលវារីអគ្គិសនីទៅទៀត។ ការអនុវត្តតាមលក្ខខណ្ឌទាំងនេះ ត្រូវប្រឈមនឹងផលប្រយោជន៍ ស្ថាប័ន និងគុណតម្លៃ ដែលមានឥទ្ធិពលមកលើប្រព័ន្ធសង្គម-អេកូឡូស៊ីទំនើប។ ប៉ុន្តែ នេះមិនមែនជាអំណះអំណាងសមស្របមួយសំរាប់ ឱ្យគេចចេញពីការពាក់ព័ន្ធជាមួយលក្ខខណ្ឌស្នូលខ្លះៗឱ្យបានច្បាស់លាស់តាមដែលអាចធ្វើបាននោះឡើយ។

ចំណុចទីពីររបស់ Gibson គឺថា អ្នកធ្វើសេចក្តីសម្រេចនានា ប្រកបដោយការប្តេជ្ញាពិតប្រាកដ ក្នុងការធ្វើឱ្យមាននិរន្តរភាព ត្រូវតែព្យាយាមបង្កើនផលវិជ្ជមាននៅក្នុងគ្រប់វិស័យស្នូលទាំងអស់មុន នឹងពិចារណាអំពីការធ្វើសម្បទាន។ ទីបី នៅពេលដែលទាមទារ ឱ្យមាន ការធ្វើសម្បទាន Gibson ពោលថាការប្រើប្រាស់គោលការណ៍ជាមូលដ្ឋាននានាអាចផ្តល់ផលវិជ្ជមាន រួមមាន :

- ផលចំណេញជាក់ស្តែងជាអតិបរមា - វិភាគទានដែលពង្រឹងគ្នាទៅវិញទៅមក ប្រមូលផ្តុំ និងសម្រាប់រយៈពេលយូរអង្វែង
- ជៀសវាងឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរ - គ្មានឥទ្ធិពលអវិជ្ជមានមកលើប្រព័ន្ធសង្គម-អេកូឡូស៊ីឡើយ លើកលែងតែជម្រើសជំនួស ដែលផ្តល់ផលប៉ះពាល់មកលើប្រព័ន្ធសង្គម-អេកូឡូស៊ីកាន់តែអាក្រក់ជាងនេះ
- ការពារអនាគត - គ្មានការបញ្ជូនផលប៉ះពាល់អវិជ្ជមានទៅអនាគតឡើយ លើកលែងតែជម្រើសជំនួស បង្កឱ្យមានការបញ្ជូន ទៅអនាគត នូវផលអវិជ្ជមានកាន់តែអាក្រក់ជាងនេះ
- ការបង្ហាញភស្តុតាងច្បាស់លាស់ - ផ្អែកលើអាទិភាពជាក់លាក់លក្ខណៈវិនិច្ឆ័យនិរន្តរភាពសំខាន់ៗ និងគោលការណ៍សម្បទាន
- ដំណើរការធ្វើសេចក្តីសម្រេចដោយបើកចំហ សម្រាប់ការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់
- បន្ទុកនៃអំណះអំណាងមកលើអ្នកលើកស្នើឱ្យមានសម្បទាន

ប្រភព : យោងតាម Gibson (2006: 176)

សេចក្តីសង្ខេបរបស់យើងអំពីក្របខ័ណ្ឌជាមូលដ្ឋានមួយ ប៉ុន្តែប្រកបដោយសារៈសំខាន់នេះ (Gibson 2006) គូសបញ្ជាក់អំពី សក្តានុពល និងដែនកំណត់នៃសេចក្តីព្រាង HSAP។ HSAP មានសក្តានុពលសម្រាប់ជាមូលដ្ឋាន នៃការធ្វើសេចក្តីសម្រេចនយោបាយ ជាសាធារណៈ។ ប៉ុន្តែ ដើម្បីបំពេញបានតាមសក្តានុពលនេះ វាទាមទារឱ្យមានលក្ខណៈវិនិច្ឆ័យ (ទិដ្ឋភាព) ជាក់លាក់ចំនួន៣៩ ដែលគូសបញ្ជាក់កាន់តែច្បាស់អំពីលក្ខខណ្ឌស្នូលនៃនិរន្តរភាព។ អ្នកពាក់ព័ន្ធនានា អាចរៀនសូត្របន្ថែមទៀតដោយប្រើប្រាស លក្ខណៈវិនិច្ឆ័យ និងសូចនាកក្នុងចំនួនតិចតួចជាងនេះ ប៉ុន្តែជាច់ខាតជាងនេះ។

# សេចក្តីសន្និដ្ឋាន

ឯកសារពិភាក្សានេះ បានណែនាំឱ្យស្គាល់អំពីសេចក្តីព្រាងពិធីសារ សម្រាប់វិភាគវាយតំលៃ អំពីនិរន្តរភាពរបស់វារីអគ្គិសនី(សំណៅខែសីហា ឆ្នាំ២០០៩) និងបានផ្តល់នូវការវិភាគលំអិតជាលើកដំបូង អំពីរបៀប ដែលពិធីសារនេះត្រូវបានបង្កើតឡើងសម្រាប់យកមកអនុវត្ត ។ការវិភាគ របស់យើង បើកកកាយអំពីដែនចំណុចខ្វះខាតមួយចំនួននៅក្នុងសេចក្តី ព្រាងនេះ។ ការខ្វះខាតជាក់ស្តែងមួយគឺ ប្រវែងវែងនិងភាពស្មុគស្មាញ នៃពិធីសារនេះ ជាពិសេសនៅក្នុងផ្នែកទី II, III, និង IV, ដែល ជាការដាក់កំហិតលើ ការចូលរួមជាសាធារណៈប្រកប ដោយការយល់ដឹងជាមុនក៏ដូចជាកំហិតលើការអនុវត្តឱ្យបានទូលំទូលាយផងដែរ ។បញ្ហា នេះ អាចដោះស្រាយបាន តាមរយៈការផ្តោតលើ លក្ខណៈវិនិច្ឆ័យដែល មានអាទិភាពខ្ពស់ក្នុងចំនួនកាន់តែតិចជាងមុន ដោយធ្វើអត្តសញ្ញាណកម្ម លក្ខណៈវិនិច្ឆ័យបែបនេះ តាមរយៈការ ពិភាក្សាជាមុន រវាងក្រុមអ្នក ពាក់ព័ន្ធ ឬ នៅក្នុងចំណោម ក្រុមអ្នកពាក់ព័ន្ធ អំពីថាតើ "លក្ខខណ្ឌស្នូល អំពីនិរន្តរភាព"ណាខ្លះ ដែលពួកគេ ចង់ធ្វើការវាយតំលៃ (សូមអានផ្នែក ទី៥) ។

ការខ្វះខាត់សំខាន់មួយផ្សេងទៀត ស្ថិតនៅត្រង់ថា សេចក្តីព្រាង ពិធីសារនេះ បានប្រើប្រាស់វិធីនៃការបកស្រាយ ។ វិធីនេះ អនុញ្ញាតឱ្យ អ្នកដើរតួនានា កំណត់អំពីតម្រូវការ លក្ខខណ្ឌ និងលទ្ធផលសំខាន់ៗ នៅ ក្រៅការវាយតំលៃនេះ។ ប្រសិនបើ ការវិភាគវាយតំលៃ និង ការវិភាគ វាយតំលៃដំណាក់កាលបឋម ត្រូវបានធ្វើឡើង ដោយមានពហុអ្នកពាក់ ព័ន្ធចំនួនតិចតួចចូលរួម ឬ ដោយប្រើប្រាស់ឧទាហរណ៏ច្បាស់លាស់អំពី ការអនុវត្តមានលក្ខណៈជឿនលឿនចំនួនតូចនោះ ផែនការថាមពល ឬ ទំនប់វារីអគ្គិសនី ដែលពុំមានលក្ខខណ្ឌល្អ អាចនឹងទទួលបានពិន្ទុខ្ពស់ ជាង ផែនការ ឬ ទំនប់ដែលបានឆ្លងកាត់ការវាយតំលៃបានម៉ត់ចត់ និងពេល លេញទៅទៀត ។

ការពិភាក្សាទៅតាមបរិបទជាក់លាក់ គឺពិតជាប្រការចាំបាច់ ។ តើ អ្វីខ្លះជាលទ្ធផលជាក់លាក់ ដែលជាការចង់បានពីទំនប់ ផែនការសេវាកម្មថាមពល ឬ ផែនការអភិវឌ្ឍន៏ថ្នាក់តំបន់ណាមួយ? យើងអាចឯក ភាពលើតម្រូវការឱ្យមានការពិភាក្សា(ជាបន្តបន្ទាប់) បែបនេះ។ ប៉ុន្តែ តាមកត្តវិទ្យា ពិធីសារនេះផ្ទាល់ មិនត្រូវពឹងផ្អែកខ្លាំងក្លាពេកទៅលើវិធី សាស្ត្រប្រៀបធៀបបែបនោះឡើយ ។ជាក់ស្តែង ដើម្បីជម្រុញឱ្យមានការ ពិភាក្សាជាសាធារណៈបែបនេះជាបន្ថែម ៖ព្រាង គួរតែផ្តល់ការណែនាំឱ្យ បានច្រើន ជាងនេះ អំពី ការអនុវត្តជឿនលឿន ដែលមានស្រាប់ សម្រាប់ លក្ខណៈវិនិច្ឆ័យ(ទិដ្ឋភាព)និរន្តរភាពទាំងអស់ ។ សេចក្តីព្រាងខែ សីហា ឆ្នាំ២០០៩ នៅពុំមាន លក្ខណៈពេញលេញបែបនេះនៅឡើយទេ។ ឧទាហរណ៏អំពីការអនុវត្តជឿនលឿនដែលត្រូវបានយកមកប្រើប្រាស់ ឬ ទទួលយកពីសំណាក់ឧស្សាហកម្មដែលពាក់ព័ន្ធនឹងថាមពល រួមមាន :

- IRP – ការកសាងផែនការសមាហរណកម្មសម្រាប់ធនធាន (D'Sa 2005)
- FPIC – ការទទួលបានការឯកភាពដោយសេរី និងដោយមាន ការយល់ដឹងជាមុនពីសំណាក់ប្រជាពលរដ្ឋរងគ្រោះដោយសារ គម្រោង (RSPO 2007)

ជាសរុប វេទិកាវិភាគវាយតំលៃកម្រិតនិរន្តរភាពនៃវារីអគ្គិសនី បានផ្តលឧបករណ៏ថ្មីមួយ សម្រាប់ការវិភាគវាយតំលៃ នៅក្នុងការកសាង ផែនការ និងការអភិវឌ្ឍន៏ថាមពលវារីអគ្គិសនី។ វិធានរបស់វេទិកានេះ ផ្តោតលើការគ្រប់គ្រងបញ្ហាជាក់ស្តែង និង កំណែលម្អជាបន្តបន្ទាប់ ឆ្ពោះ ទៅរកទម្លាប់អនុវត្តដែលមាននិរន្តរភាព ។ សេចក្តីព្រាងនីតិវិធីនេះ ប្រើប្រាស់ គំរូនៃពហុលក្ខណៈវិនិច្ឆ័យ ដែល ស្រង់យកទិដ្ឋភាពជាច្រើននៃការអនុវត្ត ដែលមាននិរន្តរភាព ប៉ុន្តែសូចនាករភាគច្រើន នៅតែត្រូវការឱ្យមានបង្ហាញ ពីចំណងទាក់ទងជា មួយស្តង់ដារមានខ្លឹមសារស៊ីជំរៅនិងជឿនលឿន។

ក្នុងខណៈដែល HSAF បានសង្កត់ធ្ងន់លើតម្រូវការឱ្យមានការវាយ តំលៃបានទូលំទូលាយ HSAF បង្ហាញតិចតួចពីរបៀបគ្រប់គ្រងលើការវាយ តំលៃ ជារបៀបដំណើរការសង្គមនៅឡើយ ។ រដ្ឋាភិបាលនិងក្រុមអ្នក

អភិវឌ្ឍន៍ គឺជាប្រភពព័ត៌មាន ដ៏សំខាន់។ តើវេទិកានេះបានលើកស្នើឡើងយន្តការអ្វីខ្លះ ដើម្បីធានាថា លទ្ធផលពីការវាយតំលៃ នឹងត្រូវលាតត្រដាងឱ្យដឹងជា សាធារណៈ? ដូចគ្នានេះដែរ តើវេទិកានេះបានលើកស្នើយន្តការអ្វីខ្លះ ដើម្បីធានាថា ភាគីទីបី ដែលមានបំណងប្រើប្រាស់ពិធីសារនេះ អាចទទួលបានភស្តុតាងពីប្រភពសំខាន់ៗ? ក្នុងនាទីជាវិធានស្ម័គ្រចិត្ត (ត្រួតត្រាខ្លួនឯង) HSAF មិនអាចចាប់បង្ខំឱ្យមានការលាតត្រដាងព័ត៌មាន ការទទួលព័ត៌មាន និងការចូលរួមនៅក្នុងកម្រិតណាមួយនោះឡើយ។ ប៉ុន្តែ ពិធីសារនេះ អាចគាំទ្រយ៉ាងមុតមាំ ដល់ស្តង់ដារកម្រិតខ្ពស់នៃអភិបាលកិច្ច ជុំវិញការប្រើប្រាស់ HSAF ។

នៅក្នុងតំបន់មេគង្គ ការសាកល្បងប្រើប្រាស់ ពិធីសារវិភាគវាយតំលៃនិរន្តរភាពរបស់វារីអគ្គិសនី សូម្បីតែវានៅក្នុងទម្រង់ជាសេចក្តីព្រាងនៅឡើយក៏ដោយ អាចផ្តល់ឱកាសថ្មីៗ សម្រាប់ការពិភាក្សាតាមទម្រង់សមស្របនិងមានន័យ។ ប្រធានបទនៃការពិភាក្សា ដែលគាំទ្រដោយការសាកល្បងអនុវត្ត HSAF រួមបញ្ចូល តម្រូវការថាមពល ជម្រើសនិងថ្លៃ ក៏ដូចជា ស្តង់ដារ ខាងសង្គម និងបរិស្ថាន សម្រាប់គម្រោងវារីអគ្គិសនីនៅក្នុងដំណាក់កាលការអភិវឌ្ឍន៍ផ្សេងៗនិងការឧបត្ថម្ភគាំទ្រផងដែរ។ បញ្ហានិរន្តរភាព នៅតំបន់ខ្សែទឹកខាងក្រោម លំហូរបរិស្ថាន និងការវាយតំលៃបញ្ហាឆ្លងព្រំដែន និងអាងទាំងមូល ក៏អាចយកមកពិនិត្យមើលបានផងដែរនៅក្នុងពេលអនុវត្តសាកល្បង។អ្នកពាក់ព័ន្ធនានា អាចរៀនសូត្របានច្រើន ដោយគ្រាន់តែប្រើប្រាស់សេចក្តី ព្រាងលក្ខណៈវិនិច្ឆ័យពីបី ទៅប្រាំមួយ នៅក្នុងផ្នែកទី១។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីពិនិត្យមើលបញ្ហាបែបនេះជាមួយពហុអ្នកពាក់ព័ន្ធនានា រាល់ការគ្រោងអនុវត្តសាកល្បង ក៏ត្រូវតែផ្តល់ឱកាសដើម្បីឱ្យមានការចូលរួមដ៏មានអត្ថន័យផងដែរ។ គេលំបាកក្នុងការមើលឃើញថា ការអនុវត្តសាកល្បងដែល មិនបើកទូលាយនោះ នឹងបំពេញតាមគោលបំណងនៃវេទិកានេះ ក្នុងការបង្កើតបច្ចេកទេសវាយតំលៃអំពីកម្រិតនិរន្តរភាពដែលមានការ គាំទ្រទូលំទូលាយដែរឬយ៉ាងណានោះ។

HSAF បានធ្វើការប្រឹងប្រែងយ៉ាងច្រើននៅក្នុងការរៀបរៀងសេចក្តីព្រាងពិធីសារនេះ ចុះខែសីហា ២០០៩។ ការកែលម្អជាបន្ថែម នឹងអាចធ្វើទៅបាន។ ដោយផ្អែកលើការសង្កេតរបស់យើងនៅក្នុងឆ្នាំ២០០៩ យើងជឿថា វេទិកានេះស្វាគមន៍យោបល់ពី សាធារណជន ព្រមទាំងពិចារណាយោបល់ទាំងនោះដោយហ្មត់ចត់ផងដែរ។

រហូតដល់ឆ្នាំ ២០១០ HSAF សង្ឃឹមថានឹងអាចរៀបរៀងជាវិធីសាស្ត្រមួយសម្រាប់វិភាគវាយតំលៃ ដែលមិនត្រឹមតែមានភាព"ជាក់ស្តែងច្បាស់លាស់ និងមិនសត្យានុម័ត"ប៉ុណ្ណោះទេ ប៉ុន្តែជាវិធីសាស្ត្រមួយ ដែលអ្នកដើរតួខុសគ្នាជាច្រើនអាចឯកភាពជាមួយផងដែរ។ ប្រសិនបើដូច្នោះមែននោះ វាគឺជាការរីកចម្រើនយ៉ាងច្រើន ធៀបនឹងស្ថានភាព ដូចសព្វថ្ងៃនេះនៅក្នុងតំបន់មេគង្គ។

# សេចក្ដីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ Helen Locher, John Dore, Louis Lebel, nig Kate Lazarus ដែលបានផ្ដល់ យោបល់ដ៏មានប្រយោជន៍ជាច្រើន ។

១-ពិធីសារសំរាប់ការវិភាគវាយតំលៃនិរន្តរភាព IHA (2006) គឺជាគោលការណ៍ស្ម័គ្រចិត្តមួយ ដែលបានរៀបរៀងឡើងដោយ IHA ដើម្បីវាយតំលៃអំពីដំណើរការ នៃគម្រោង ធៀបនឹងគោលការណ៍ណែនាំនិរន្តរភាពរបស់ IHA (2004)

២-អ្នកឧបត្ថម្ភចំបងរបស់វេទិកានេះ គឺរដ្ឋាភិបាលនៃប្រទេសន័រវែស អាល្លឺម៉ង់ និងអាយស្លែន។ នៅឆ្នាំ ២០០៩, វេទិកានេះ មានសមាជិកពីររូបមកពីវិស័យវារីអគ្គិសនី (Hydro Tasmania; IHA); ពីររូបមកពីវិស័យហិរញ្ញវត្ថុ (តំណាងមួយរូបមកពីគ្រឹះស្ថានហិរញ្ញវត្ថុគោលការណ៍អេក្វាទ័រ និងអ្នកសង្កេតការណ៍ មួយរូបមកពីធនាគារពិភពលោក) សមាជិកបួនរូបមកពី NGOs អន្តរជាតិ (មូលនិធិពិភពលោកសម្រាប់អភិរក្សសត្វព្រៃ អង្គការអភិរក្សធម្មជាតិ អង្គការតម្លាភាពអន្តរជាតិ និងអុកស្វាមប៉ុ និងតំណាងប្រាំមួយរូបមកពីរដ្ឋាភិបាល (នៃប្រទេសន័រវែស អាយស្លែន អាល្លឺម៉ង់ ចិន (2), និងហ្សំប៊ី) ។

អតិថិជន ចរចាអំពីការទិញថាមពលពីគម្រោងនានា ដែលបានកើតចេញពីដំណើរការពីថ្នាក់ក្រោមមកថ្នាក់ខ្ពស់ ។ ជាទូទៅ ដំណើរការនេះចាប់ផ្ដើមដោយ ក្រុមអ្នកអភិវឌ្ឍន៍ធ្វើការដេញថ្លៃដើម្បីទទួលបានសិទ្ធិផ្ដាច់មុខពីរដ្ឋាភិបាលសម្រាប់ការអង្កេតទីតាំងនានា។ បន្ទាប់មកក្រុមអ្នកអភិវឌ្ឍន៍ បន្តធ្វើការកែលម្អចំណេះ ដឹងកាន់តែច្រើនឡើងអំពីផលប៉ះពាល់ ការចំណាយ និងផលចំណូល ។ ចំណេះដឹងនេះគាំទ្រដល់កិច្ចព្រមព្រៀងមួយចំនួន ដែលកើតចេញពីការចរចារវាងរដ្ឋាភិបាល និងអ្នកទិញ ។ កិច្ចព្រមព្រៀងនានា កាន់តែមានភាពសាំញ៉ាំ។ នៅពេលក្រោយមកសាធារណជនចាប់ផ្ដើមស្វែងយល់អំពីសេចក្ដីលំអិតនៃគម្រោង និងចូលរួមនៅ ក្នុងការពិគ្រោះយោបល់នានា។ ជាអកុសល នៅក្នុងដំណាក់កាលនេះ ភាពទន់ភ្លន់របស់អ្នកឧបត្ថម្ភ ដើម្បីកែលម្អការអនុវត្តខាងផ្នែកបរិស្ថាន និងសង្គម ជាការឆ្លើយតបទៅនឹងយោបល់ពីសាធារណជន ក៏បានថយចុះផងដែរ ។

ចំពោះតម្រូវការដែលអាចបង្ហាញជាក់លាក់ សូចនាករដែលជិតស្និទ្ធបំផុត ដែលទាក់ទងនឹងចំណុចនេះគឺ "គុណភាពនៃការពិគ្រោះយោបល់ ដែលទាក់ទងនឹង តម្រូវការដែលអាចបង្ហាញថាជាក់លាក់" ។

នៅក្រោមបច្ចេកវិទ្យាសព្វថ្ងៃនេះ ផែនការ និងគម្រោងមិនល្អ ដែលបានវាយតំលៃតាមរយៈការចូលរួមនៃពហុអ្នកពាក់ព័ន្ធក្នុងកម្រិតកំណត់ អាចផ្ដល់ពិន្ទុខ្ពស់ជាងផែនការ និងគម្រោងនានា ដែលបានវាយតំលៃដោយហ្មត់ចត់ និងពេញលេញ ។

ក្នុងន័យនេះ វេទិកានេះ និងអ្នកពាក់ព័ន្ធនៅក្នុងវេទិកានេះ បានធ្វើអត្តសញ្ញាណរួចមកហើយនូវបញ្ហាសំខាន់ៗនិងដែលមានលក្ខណៈអន្តរវិស័យ ដូចជាសិទ្ធិមនុស្ស បញ្ហាអាងទន្លេនិងឆ្លងដែនការប្រែប្រួលអាកាសធាតុ អំពើពុករលួយ ការប្រាស្រ័យឆ្លើយឆ្លង តម្លាភាព យេនឌ័រ យន្តការសំរាប់ទទួលបណ្ដឹងតវ៉ា ការចិញ្ចឹមជីវិត និង វារីអគ្គិសនីពហុបំណង ។

ការប្រើប្រាស់ចំនួន ដើម្បីសង្ខេបលទ្ធផល បង្កើតឱ្យមានអារម្មណ៍ខុសឆ្គងអំពីគោលបំណង ។

# ឯកសារយោង


ARUP. 2009. HSAF Phase I Consultation: Consultation Outcomes Report. 27 February 2009. Leeds: Ove Arup & Partners Ltd.

Blaauw, Martijn, and Duncan Pritchard. 2005. *Epistemology A–Z*. Edinburgh: Edinburgh University Press.

Cavallo, Ernesto, Shannon Lawrence, and Aviva Imhof. 2008. Poverty Reduction in Laos: an Alternative Approach. In *Power Surge*, edited by S. Lawrence. Berkeley, CA: International Rivers.

D'Sa, Antonette. 2005. Integrated resource planning (IRP) and power sector reform in developing countries. *Energy Policy* 33:1271–1285.

Dore, John, Louis Lebel, and Jesse Manuta. 2004. Gaining Public Acceptance: a Strategic Priority of the World Commission on Dams. Background Paper for Proposed GPA E-Conference. Prepared for United Nations Environment Program (UNEP) Dams and Development Project (DDP). Chiang Mai: Unit for Social and Environmental Research.

du Pont, Peter. 2005. Nam Theun 2 Hydropower Project (NT2). Impact of Energy Conservation, DSM, and Renewable Energy Generation on EGAT's Power Development Plan. Bangkok: World Bank.

Dubash, Navroz K., Mairi Dupar, Smitu Kothari, and Tundu Lissu. 2001. *A Watershed in Global Governance? An Independent Assessment of the World Commission on Dams:* World Resources Institute, Lokayan and Lawyer's Environmental Action Team.

Equator Principles. The Equator Principles: *A benchmark for the financial industry to manage social and environmental issues in project financing* 2006 Available from http://www.equator-principles.com/principles.shtml.

Foran, Tira. 2009. Good principles in search of better developers? The Equator Principles and Mekong infrastructure development. USER Working Paper 2009-15-WP. Chiang Mai, Thailand: Chiang Mai University, Unit for Social and Environmental Research (USER).

Foran, Tira, and Kanokwan Manorom. 2009. Pak Mun Dam: Perpetually Contested? Chapter 3. In *Contested Waterscapes in the Mekong Region: Hydropower, Governance and Livelihoods*, edited by F. Molle, T. Foran and M. Kakonen. London: Earthscan Publications Ltd.

Gibson, Robert B. 2006. Sustainability assessment: basic components of a practical approach. *Impact Assessment and Project Appraisal* 24 (3):170–182.

Greacen, C. E., and Apsara Palettu. 2007. Electricity sector planning and hydropower. In *Democratizing Water Governance*, edited by L. Lebel, J. Dore, R. Daniel and Y. S. Koma. Chiang Mai: Mekong Press.

Hydropower Sustainability Assessment Forum. 2009a. Draft Hydropower Sustainability Assessment Protocol – August 2009. Available (in four sections) from: http://www.hydropower.org/sustainable_hydropower/HSAF_Hydropower_Sustainability_Assessment_Protocol.html. International Hydropower Association, London.

Hydropower Sustainability Assessment Forum. 2009b. Mapping of the World Commission on Dams Strategic Priorities within the Draft Hydropower Sustainability Assessment Protocol Content. August 2009. Available from: http://www.hydropower.org/sustainable_hydropower/HSAF-Mapping_of_WCD_Strategic_Priorities_within_the_Draft_HSAP_Content_August_2009.pdf. International Hydropower Association, London.

International Finance Corporation. 2006. International Finance Corporation's Performance Standards on Social & Environmental Sustainability. 30 April 2006.

International Hydropower Association. 2003. The Role of Hydropower in Sustainable Development. IHA White Paper February 2003. Sutton, Surrey, UK: International Hydropower Association.

International Hydropower Association. 2006. Sustainability Assessment Protocol. London: International Hydropower Association.

International Hydropower Association. 2009a. Hydropower Sustainability Assessment Forum. Response to Consultation Phase 1 Issues. (March 2009). London: International Hydropower Association.

International Hydropower Association. 2009b. Hydropower Sustainability Assessment Protocol. Key components document. A consultation document for the work of the Hydropower Sustainability Assessment Forum Phase 1 Consultation, January–February 2009. International Hydropower Association.

International Rivers. 2008. Social and Environmental Standards for Large Dams. Comparing the Strategic Priorities and Policy Principles of the World Commission on Dams, the Sustainability Guidelines and Sustainability Assessment Protocol of the International Hydropower Association, and the Performance Standards of the World Bank's International Finance Corporation. December 2008. Berkeley, CA: International Rivers.

Lebel, Louis, John Dore, Rajesh Daniel, and Yang Saing Koma, eds. 2007. *Democratizing water governance in the Mekong region*. Chiang Mai: Mekong Press.

Molle, Francois, Tira Foran, and Mira Käkönen, eds. 2009. *Contested Waterscapes in the Mekong Region: Hydropower, Governance and Livelihoods*. London: Earthscan Publications Ltd.

Roundtable on Sustainable Palm Oil. 2007. RSPO Principles and Criteria for Sustainable Palm Oil Production. Including indicators and guidance. Available from: http://www.rspo.org/resource_centre/RSPO%20Principles%20&%20Criteria%20Document.pdf. Kuala Lumpur: Roundtable on Sustainable Palm Oil Secretariat.

Sayer, Andrew. 2000. Realism in Social Science. London: Sage.

Simon, Michael. 2009. Consulting impacted peoples. Presentation given to Hydropower Sustainability Assessment Forum. Meeting 5. Itaipu, Brazil. 9 December 2008. Melbourne: Oxfam Australia.

Ubon Ratchatani University [UBU]. 2002. *Khrong kan sueksa naew tang fuen fu rabop niwet withi chiwit lae chumchon thi dai rap phon krathop chak kan sang khuean pak mun* [Project to Study Approaches to Restoration of the Ecology, Livelihood, and Communities Receiving Impacts from Construction of Pak Mun Dam].Ubon Ratchatani: Ubon Ratchatani University.

World Commission on Dams. 2000. *Dams and Development: A New Framework for Decision-Making*. London: Earthscan Publications Ltd.

Wright, Christopher, and Alexis Rwabizambuga. 2006. Institutional Pressures, Corporate Reputation, and Voluntary Codes of Conduct: An Examination of the Equator Principles. *Business and Society Review* 111 (1):89–117.

## ព័ត៌មានបន្ថែម

សមាគមថាមពលវារីអគ្គិសនីអន្តរជាតិ International Hydropower Association: www.hydropower.org/sustainable_hydropower/hsaf.html

M-POWER

Mekong Program on Water
Environment and Resilience

**M-POWER** (កម្មវិធីមេគង្គស្តីពីទឹក បរិស្ថាន និងភាពធន់ www.mpowernet.org) គឺជាកិច្ចសហប្រតិបត្តិការស្រាវជ្រាវមួយ ក្នុងចំណោមអង្គការនានាដែលធ្វើការស្រាវជ្រាវ និងផ្តោតលើគោលនយោបាយ ដែលធ្វើសកម្មភាពនៅក្នុងតំបន់មេគង្គ។ គោលដៅចុងក្រោយរបស់ M-POWER គឺកែលម្អសន្តិសុខលើការចិញ្ចឹមជីវិត សុខភាពមនុស្ស និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់មេគង្គ តាមរយៈការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មនៃអភិបាលកិច្ចទឹក។ ជាជាងធ្វើការសន្មតិថា មានគំរូតែមួយនៃប្រជាធិបតេយ្យភាវូបនីយកម្មដែលសមស្របសម្រាប់គ្រប់បរិបទ យើងជឿថា ការស្រាវជ្រាវតាមរយៈសកម្មភាពផ្ទាល់ អាចជួយសង្គមក្នុងការស្វែងយល់ និងធ្វើការកែទម្រង់តាមរយៈការបន្សាំទៅនឹងអភិបាលកិច្ចទឹក។ គម្រោងកែលម្អការវិនិយោគទឹកនៅក្នុងតំបន់មេគង្គ មានគោលដៅស្វែងយល់ និងជួយកែលម្អអភិបាលកិច្ចនៃការធ្វើសេចក្តីសម្រេចនៅជុំវិញការអភិវឌ្ឍធនធានថាមពលនិងទឹកនៅក្នុងតំបន់មេគង្គ។ យើងចាត់ទុកការកសាងផែនការសមាហរណកម្មធនធានអគ្គិសនី (IRP), និងកិច្ចផ្តួចផ្តើមស្ម័គ្រចិត្ត (ដូចជា ការប្រើប្រាស់ HSAP) ថាជាការអនុវត្តដែលមានសារៈសំខាន់ ដែលនៅពេលបានអនុវត្តតាមបែបផែននៃការចូលរួមអាចកែលម្អការ ធ្វើសេចក្តីសម្រេចនៅជុំវិញអនាគតនៃថាមពល និងថាមពលវារីអគ្គិសនី។